# របាយការណ៍
# រីកចម្រើនប្រចាំឆ្នាំ

២០០៩



## ទស្សនវិស័យរបស់យើង

គឺចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍

## សេចក្តីអធិស្ឋានរបស់យើង

សូមឱ្យទឹកចិត្តមនុស្សគ្រប់រូប មានឆន្ទៈដើម្បីសម្រេចបំណងនេះ

# សារលិខិតរបស់នាយិកាប្រចាំប្រទេស



ឆ្នាំសារពើពន្ធ ២០០៩ បានបញ្ចប់ទៅហើយ ប្រទេសកម្ពុជាចាប់ផ្តើមរងផលប៉ះពាល់ពីដំណើរថយក្រោយការរីកចម្រើនរបស់សាកលលោក ។ សូមថ្លែងអំណរគុណចំពោះការប្តេជ្ញាចិត្តយ៉ាងមុតមាំពីអ្នកទាំងអស់គ្នាចំពោះការសហការពីសំណាក់រាជរដ្ឋាភិបាល និងដៃគូផ្សេងៗរបស់យើង អ្នកទំនុកបម្រុងកុមារ និងអ្នកគាំទ្ររបស់យើង ដូចជា ព្រះវិហារជាដៃគូ អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់របស់យើង ។ ដោយសារអ្នកទាំងអស់គ្នាទើបអង្គការទស្សនៈពិភពលោកអាចឆ្លងកាត់ការចាប់ផ្តើមនៃវិបត្តិសាកលលោកនេះ ។

កម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការទស្សនៈពិភពលោកចំនួន ៣៨ ប្រចាំនៅសហគមន៍កំពុងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងប្រជាពលរដ្ឋកម្ពុជាដើម្បីធានាឱ្យបានថា កុមារត្រូវបានការពារ និងថែទាំ ទោះបីជាស្ថិតនៅក្នុងស្ថានភាពធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរនៃសេដ្ឋកិច្ចក៏ដោយ ។ ស្របពេលដែលគ្រួសាររបស់សហគមន៍កំពុងប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុ អង្គការទស្សនៈពិភពលោកកាន់តែរួសរាន់បន្តភារកិច្ចរបស់ខ្លួន បំផុសចលនាសហគមន៍ដើម្បីធានាថាកុមាររបស់យើងកំពុងបន្តការសិក្សា មានអាហារដែលមានគុណភាពដល់សុខភាពសម្រាប់បរិភោគ ប្រកាន់ខ្ជាប់នូវអនាម័យត្រឹមត្រូវ និងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍន៍ ។ សេចក្តីប្តេជ្ញាចិត្តរបស់យើងចំពោះកុមារកំព្រា និងងាយរងគ្រោះដោយសារជំងឺអេដស៍នៅតែមុតមាំ ហើយយើងទទួលបានការលើកទឹកចិត្តតាមរយៈការយល់ដឹងកាន់តែច្រើនឡើងរបស់ប្រជាជន អំពីសារៈសំខាន់នៃការអភិវឌ្ឍយុវជនយុវនារីជំនាន់ក្រោយ ។ យើងកំពុងតែឈានចូលឆ្នាំសារពើពន្ធ ២០១០ យើងសូមអធិស្ឋានទៅព្រះជាម្ចាស់ឱ្យទ្រង់បានជួយយើងឆ្លងកាត់ពេលវេលាដ៏លំបាកចំពោះមុខ ។

ជារៀងរាល់ថ្ងៃយើងទទួលបានព័ត៌មានអំពីការបិទរោងចក្រកាត់ដេរជាបន្តបន្ទាប់ ហើយយុវជន និងយុវនារីដែលជាកម្មកររោងចក្របានបាត់បង់ការងាររបស់ខ្លួន ។ ប្រជាជនក្រីក្រនៅទីប្រជុំជន និងប្រជាជនក្រីក្របំផុតនៅតាមតំបន់ជនបទ គឺជាអ្នកដែលទទួលផលប៉ះពាល់ខ្លាំងជាងគេដោយសារវិបត្តិសេដ្ឋកិច្ចនេះ ។ ដោយសារការផ្ញើលុយឧបត្ថម្ភពីទីក្រុង ក៏ដូចជាពីក្រៅប្រទេសកាន់តែតិចទៅៗសមាជិកគ្រួសារនៅតាមទីជនបទត្រូវក្លាយជាអ្នកងាយរងគ្រោះ ព្រោះពួកគេមិនអាចរកចំណូលគ្រប់គ្រាន់ដើម្បីបំពេញសេចក្តីត្រូវការ ចំពោះការឡើងថ្លៃនៃសេវាសុខភាព និងម្ហូបអាហារ ។ ប្រជាជនងាយរងគ្រោះបំផុតមួយចំនួនដែលទទួលរងផលប៉ះពាល់ គឺប្រជាជនក្រីក្រ និងគ្រួសារមួយចំនួនដែលនៅដាច់ស្រយាល ជាពិសេសកូនៗរបស់ពួកគាត់ ។ ការស្រាវជ្រាវថ្មីមួយរបស់សមាគមន៍សេដ្ឋកិច្ចកម្ពុជាបានបង្ហាញថា ៨៩% នៃភូមិដែលបានសាកសួរ រាយការណ៍ពីស្ថានភាពលំបាក

ជាច្រើនប្រភេទ ។ ឧបសគ្គមួយចំនួនដែលគ្រួសារទាំងនោះកំពុងប្រឈមរួមមានៈ ការថយចុះយ៉ាងសម្បើមនៃចំណូល ការកើនឡើងនៃការចំណាយទៅលើការថែទាំសុខភាព តម្លៃថ្លៃរបស់ម្ហូបអាហារ និងបន្ទុកនៃការសងបំណុល ។

សូចណាករមួយចំនួនអំពីពេលវេលាដ៏លំបាកនៅចំពោះមុខត្រូវបានបង្ហាញតាមរយៈការសិក្សាថ្នាក់ជាតិមួយឱ្យឃើញថា មានចំនួនកុមារនៅទីប្រជុំជន ដែលខ្វះអាហារូបត្ថម្ភមានការកើនឡើងពី ៩,៦% ក្នុងឆ្នាំ ២០០៥ កើនទៅ ១៥,៩% ក្នុងឆ្នាំ ២០០៨ ។ គ្រួសារដែលនៅតាមទីប្រជុំជន ក៏ដូចជានៅតំបន់ជនបទ បរិភោគអាហារដែលមានសារជាតិប្រូតេអ៊ីនតិចជាងមុន ។ ឪពុក-ម្តាយរបស់កុមារមិនមានថវិកាគ្រប់គ្រាន់ក្នុងការចំណាយទៅលើការថែទាំសុខភាពមូលដ្ឋានដូចដែលគាត់ធ្លាប់មាន ។ កុមារកាន់តែច្រើនរងទុក្ខដោយសាររោគរាករូស ការឆ្លងជំងឺផ្លូវដង្ហើម និងការគ្រុនក្តៅដោយសារជំងឺផ្សេងៗ ដែលភាគច្រើនបង្កមកពីកង្វះអាហារូបត្ថម្ភ ។

ទោះបីជាពេលវេលាលំបាកដែលមិនអាចជៀសរួចនៅចំពោះមុខយ៉ាងណាក៏ដោយ យើងនៅតែបន្តអះអាងអំពីការប្តេជ្ញាចិត្តរបស់យើងចំពោះសុខុមាលភាពរបស់កុមារកម្ពុជា គ្រួសារ និងសហគមន៍របស់ពួកគេ ។ ជាមួយនឹងការបន្តគាំទ្រ និងភាពជាដៃគូរបស់អ្នក យើងប្រាថ្នាចង់ក្លាយជាផ្នែកមួយនៃចលនាសាកលលោកដែលធ្វើការដើម្បីរួមចំណែក និងព្យាយាមសំរេចឱ្យបាននូវទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍តាមរយៈសកម្មភាពកម្មវិធីរបស់យើង ។

**ដោយក្តីគោរពរាប់អាន**



**អែរស្ទើរ ហាលីម**
**នាយិកាប្រចាំប្រទេស**

# កម្មវិធីអភិវឌ្ឍន៍តំបន់ រួមចំណែកឱ្យកុមារ មានការអប់រំ និងសុខភាពកាន់តែប្រសើរឡើង

គំរូកម្មវិធីស្នូលរបស់អង្គការទស្សនៈពិភពលោកកម្ពុជាគឺ កម្មវិធីអភិវឌ្ឍន៍តំបន់ (ADP) ។ ជាទូទៅកម្មវិធីអភិវឌ្ឍន៍តំបន់មួយមានគម្រោងពី ពីរទៅប្រាំ ដែលគម្រោងនីមួយៗ ផ្តោតលើកុមារជាចំបងដោយមានការព្រមព្រៀងពីដៃគូក្នុងសហគមន៍។ ក្រុមការងារកម្មវិធីតាមផ្នែករបស់យើង ជួយធានាឱ្យកម្មវិធីទាំងនេះសហការគ្នា ដើម្បីបង្ហាញការអនុវត្តន៍ដ៏ប្រសើរ និងជួយកសាងសមត្ថភាពរបស់បុគ្គលិកកម្មវិធីអភិវឌ្ឍន៍តំបន់ ដើម្បីធានាឱ្យមានផលប៉ះពាល់ធំបំផុតលើការធ្វើឱ្យសុខុមាលភាពកុមារប្រសើរឡើង។ ក្នុងកំឡុងពេលប្រហែល ១៥ ឆ្នាំ កម្មវិធីអភិវឌ្ឍន៍តំបន់មួយនៅប្រទេសកម្ពុជានឹងមានប្រជាជនរហូតដល់ ២៥.០០០ នាក់ នៅក្នុងភូមិប្រហែល ៣០។ ទោះបីជាកម្មវិធីអភិវឌ្ឍន៍តំបន់ទទួលការគាំទ្រផ្នែកថវិកាពីប្រភពជាច្រើន តែថវិកាស្នូលបានមកពីកម្មវិធីទំនុកបម្រុងកុមារ។

នៅឆ្នាំ ២០០៩ អង្គការទស្សនៈពិភពលោកកម្ពុជា បានអនុវត្តកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ៣៨ នៅក្នុងខេត្ត ៨ និងក្រុងភ្នំពេញ ដែលមានកុមារចំនួន ៥៥.០០០ នាក់ ចុះឈ្មោះក្នុងកម្មវិធីទំនុកបម្រុង។ កម្មវិធីអភិវឌ្ឍន៍តំបន់ធ្វើការជាមួយកុមារ និងក្រុមគ្រួសារទាំងអស់ទៅតាមតម្រូវការរបស់គេ ប៉ុន្តែធានាឱ្យកុមារទំនុកបម្រុង និងគ្រួសារគេបានរាប់បញ្ចូលក្នុងចំណោមអ្នកបានទទួលផលដំបូង។ យើងផ្តោតលើចលនាគ្រួសារ ក្រុមតាមមូលដ្ឋាន អង្គការ និង អាជ្ញាធរ ធ្វើការជាមួយគ្នាជាដៃគូដើម្បីបង្កើន និងទ្រទ្រង់សុខុមាលភាពរបស់កុមារ ដើម្បីធានាថាពួកគេទទួលការអប់រំសម្រាប់ជីវិត ទទួលបានសុខភាពល្អ មានគេយកចិត្តទុកដាក់ ការពារ និងបានចូលរួមក្នុងជីវិតសហគមន៍របស់ពួកគេ។

ដើម្បីធ្វើឱ្យគុណភាពអប់រំសម្រាប់កុមារប្រសើរឡើង កម្មវិធីអភិវឌ្ឍន៍តំបន់បានរៀបចំក្រុមគាំទ្រសាលាដែលមានឪពុកម្តាយ និងគ្រូដើម្បីលើកស្ទួយស្តង់ដា"សាលាកុមារមេត្រី" ក្នុងបំណងធ្វើឱ្យបរិយាកាស ការសិក្សានៅសាលាមានលទ្ធផលល្អបន្ថែមទៀត និងបណ្តុះបណ្តាលគ្រូបង្រៀនអំពីវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល។ នៅតាមតំបន់ដាច់ស្រយាលដែលធនធានរដ្ឋាភិបាលមានកំណត់ អង្គការទស្សនៈពិភពលោកក៏គាំទ្រឱ្យមានលទ្ធភាពទទួលការអប់រំជាមូលដ្ឋានតាមរយៈការសាងសង់ និងជួសជុលសាលាទាំងឡាយ។ នៅឆ្នាំ ២០០៩ អង្គការទស្សនៈពិភពលោក ជួយសាងសង់អាគារសាលា





ថ្មីចំនួន ១០ និងជួសជុលអាគារឱ្យមានភាពប្រសើរចំនួន ១៤។ កម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការទស្សនៈពិភពលោកធ្វើការជាមួយសហគមន៍ដើម្បីរៀបចំកុមារត្រៀមចូលសាលាថ្នាក់មត្តេយ្យ សម្របសម្រួលក្លិបកុមារ និងយុវជន និងផ្តល់ឱកាសឱ្យយុវជនរៀនជំនាញ។

ការផ្តោតសំខាន់របស់កម្មវិធីអភិវឌ្ឍន៍ភាគច្រើន គឺលើសុខភាពកុមារ និងអាហារូបត្ថម្ភ។ ដើម្បីដោះស្រាយកម្រិតខ្ពស់នៃជំងឺក្រិនដែលកើតឡើងនៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជានៅឆ្នាំ២០០៩កម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន១១បានចាប់ផ្តើមអនុវត្តកញ្ចប់ពិសេសសម្រាប់កុមារសុខភាពមាតា និងអាហារូបត្ថម្ភ ដែលផ្តោតលើកុមារដែលមានអាយុក្រោម ២ ឆ្នាំ និងម្តាយរបស់ពួកគេ។ កញ្ចប់នៃអន្តរាគមន៍នេះបានត្រូវពង្រីកនៅឆ្នាំ ២០១០ និង ២០១១ ទៅដល់កម្មវិធីអភិវឌ្ឍន៍តំបន់ទាំង ២៦។ នៅឆ្នាំ ២០០៩ មានស្ត្រីជាម្តាយជាង ៨.៥០០ មានឱកាសបានចូលរៀនសូត្រ ដើម្បីជួយឱ្យពួកគេចេះបង្កើនសុខភាព និងអាហារូបត្ថម្ភសម្រាប់កូនៗពួកគេ។

ទឹកស្អាត អនាម័យស្អាត គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ធ្វើឱ្យសុខភាពកុមារប្រសើរឡើង។ នៅឆ្នាំ២០០៩ កម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ២២ មានគម្រោងគាំទ្រផ្ទាល់ដើម្បីពង្រឹងលើផ្នែកទាំងនេះ។ អង្គការទស្សនៈពិភពលោកកម្ពុជា គាំទ្រដៃគូសហគមន៍ដើម្បីកសាងអណ្តូងខួងចំនួន ២៦៨ និងស្តារអណ្តូងខួងឡើងវិញចំនួន ១៤៩ ជីកអណ្តូងចំហថ្មីចំនួន ៥៥ និងស្តារអណ្តូងចំហឡើងវិញចំនួន ៩៧ ថែមទៀត។ អង្គការទស្សនៈពិភពលោកក៏បានជួយគាំទ្រកំលាំងដែលដឹកនាំដោយសហគមន៍ ដើម្បីជីកស្រះគ្រួសារ ១៩ និងស្រះសហគមន៍ ២០ ដើម្បីចិញ្ចឹមត្រី ដាំបន្លែ ផ្ទុកទឹក និងធ្វើប្រឡាយដូចជា សាងសង់ប្រព័ន្ធប្រមូលទឹកភ្លៀងចំនួន ៤០៤។ វិធីសាស្ត្រសហគមន៍ដឹកនាំអនុវត្តន៍អនាម័យត្រូវបានណែនាំដោយកម្មវិធីអភិវឌ្ឍន៍តំបន់មួយចំនួន ជម្រុញលើកទឹកចិត្តឱ្យមានឥរិយាបថលើកកំពស់អនាម័យ និងលើកទឹកចិត្តឱ្យមានការសាងសង់បង្គន់ដែលមានតម្លៃថោកដែលប្រើប្រាស់ធនធានមូលដ្ឋាន។ នៅតាមកម្មវិធីអភិវឌ្ឍន៍តំបន់ដែលមានអនាម័យរួម នៅក្នុងសហគមន៍ដែលមិនអាចធ្វើបាន អង្គការទស្សនៈពិភពលោក ចាប់ដៃគូជាមួយសហគមន៍ដើម្បីសាងសង់បង្គន់ជាង ១.៨០០។ អង្គការទស្សនៈពិភពលោកបានផ្តល់ការគាំទ្រដល់រាល់កម្មវិធីអភិវឌ្ឍន៍ទាំងអស់ ដើម្បីបណ្តុះបណ្តាលដល់ភ្នាក់ងារសុខភាពចំនួន ១.៩៧៩ អ្នកស្ម័គ្រចិត្តខាងសុខភាពភូមិចំនួន ៣.៩៥៣ និងគ្រូបង្រៀនចំនួន ១.៩១១ ដើម្បីលើកស្ទួយអនុវត្តន៍អនាម័យស្អាត។

# របៀបថ្មីនៃការដឹកនាំ



សាឡេះ ខលេស  អាយុ ១៨ឆ្នាំ
ជនជាតិខ្មែរ-ម៉ូស្លីម

សាឡេះ ខលេស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ-ម៉ូស្លីម ជាប្រធានក្រុមយុវជនស្ម័គ្រចិត្តដើម្បីបម្រើសហគមន៍។ ខលេស ដឹកនាំក្រុមប្រកបដោយតម្លាភាព និងលទ្ធិប្រជាធិបតេយ្យ។ ខលេស រៀបរាប់ពីរបៀបនៃការដឹកនាំថា "រាល់ការសម្រេចចិត្តទាំងឡាយ ផ្អែកលើមតិភាគច្រើន។ ខ្ញុំមិនលំអៀងទៅរកនរណាម្នាក់នោះឡើយ។  ខ្ញុំចែករំលែកទំនួលខុសត្រូវការងារស្មើៗគ្នា។ ខ្ញុំតែឯងមិនអាចធ្វើការបានដោយជោគជ័យ និងមានប្រសិទ្ធិភាពឡើយ។"

ខលេស  ពន្យល់ថា "គោលបំណងនៃការបង្កើតក្រុមនេះ គឺដើម្បីធ្វើការរួមគ្នា ដើម្បីកសាងសហគមន៍តាមរយៈការចែករំលែកចំណេះដឹង និងការលើកកម្ពស់ការយល់ដឹង (ពីសិទ្ធិកុមារ និងការកសាងសន្តិភាព)។"

បន្ទាប់ពីបានទទួលការបណ្តុះបណ្តាល ខលេស និងសមាជិកក្រុមរបស់ខ្លួន បានធ្វើសកម្មភាពជាច្រើនដែលរួមមាន ការដើរដង្ហែក្បួន ដើម្បីលើកកម្ពស់សន្តិភាព ការសម្តែងរឿងអប់រំនៅតាមវត្តអារាម និងការបង្រៀនដល់មិត្តភក្តិ និងកុមារដទៃទៀតអំពីសីលធម៌ និងការកសាងសន្តិភាព។

"ខ្ញុំចង់ចែករំលែកចំណេះដឹង  និងបទពិសោធន៍ដែលបានរៀនទៅដល់កុមារ។  ចង់ឱ្យពួកគេមានសង្ឃឹម  និងមានការផ្លាស់ប្រែដូចជាសមាជិកក្រុមដទៃទៀត។"

ខលេស បានរៀបរាប់ឱ្យដឹងថា "ខ្ញុំចង់ចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលខ្ញុំបានរៀន ទៅដល់កុមារ ។ ខ្ញុំចង់ឱ្យពួកគេមានសង្ឃឹម និងមានការផ្លាស់ប្រែដូចជាសមាជិកក្រុមដទៃទៀត ។ "

លោក ជ្រិន រឿន មេឃុំពាមរាំង ខេត្តកណ្ដាល បានមានប្រសាសន៍ថា "វាជាការល្អដែលពួកគេបង្កើតក្រុមមួយដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ។ វាមានភាពងាយស្រួលដែលយើងអាចធ្វើការជាមួយពួកគេ ។ ខ្ញុំក៏សរសើរដល់ពួកគេផងដែរ ដែលចង់ដឹងអំពីផែនការ និងថវិកាសម្រាប់ការអភិវឌ្ឍន៍សហគមន៍ ។"

ខលេស មានក្ដីស្រមៃចង់បានសហគមន៍មួយមានសន្តិភាព ដែលប្រជាជនរស់នៅប្រកបដោយសុភមង្គល មានជីវភាពរស់នៅប្រសើរឡើង ហើយកុមារមានការអប់រំខ្ពស់ ។

ខលេស បន្តទៀតថា "យើងមានផែនការជ្រើសរើសយុវជនស្ម័គ្រចិត្តបន្ថែមទៀត ដែលមានបំណងចង់ធ្វើការជាមួយយើងដើម្បីបម្រើសហគមន៍ ។ ហើយយើងក៏នឹងបណ្ដុះបណ្ដាលកុមារនូវអ្វីដែលយើងបានរៀន ។"

ខលេស បញ្ជាក់ថា "ខ្ញុំមិនបានចំណេញអ្វីពីការដែលធ្វើជាប្រធានក្រុមទេ ប៉ុន្តែខ្ញុំសប្បាយចិត្តខ្លាំងណាស់ក្នុងការធ្វើជាប្រធានក្រុម ពីព្រោះខ្ញុំចង់ទទួលបានបទពិសោធន៍សម្រាប់ជីវិត និងចែករំលែកចំណេះដឹងជាមួយកុមារ ។"





# ការតស៊ូមតិ

ឆ្នាំសារពើពន្ធ ២០០៩ ជាឆ្នាំដ៏ល្អមួយសម្រាប់ការងារជាដៃគូ និងការសហការគ្នា ។ ក្រុមការងារតស៊ូមតិនៃអង្គការទស្សនៈពិភពលោកកម្ពុជា បានសហការយ៉ាងសកម្មជាមួយអង្គការក្រៅរដ្ឋាភិបាល ក្រសួងរដ្ឋាភិបាលនានា និងសហគមន៍ដទៃទៀតដើម្បីធានាឱ្យកុមារមានសំលេងនៅក្នុងអភិបាលកិច្ច ដោយធ្វើការសហការជាមួយវិទ្យាស្ថានខ្មែរសម្រាប់អភិវឌ្ឍន៍ជាតិ និងអង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង ។ យើងអាចបណ្តុះបណ្តាលដល់ក្រុមយុវជនចំនួន ៤០០ នាក់ដែលមកពីឃុំចំនួន ១៦ នៃតំបន់ជាយក្រុងភ្នំពេញឱ្យចូលរួមក្នុងការប្រជុំក្រុមប្រឹក្សាសង្កាត់ (ជាអភិបាលកិច្ចថ្នាក់មូលដ្ឋាន) ពីគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់ ។ ក្រុមយុវជនជាង ៦០ នាក់ មកពីស្រុកជលគីរី ខេត្តកំពង់ឆ្នាំង និងជាង ៥០ នាក់មកពីក្រុមកុមារនៃអង្គការទស្សនៈពិភពលោក បានទទួលចំណេះដឹងយ៉ាងច្រើនស្តីពីអភិបាលកិច្ចថ្នាក់មូលដ្ឋាន ។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលនោះមក យុវជនទាំងអស់ត្រូវបានអញ្ជើញឱ្យចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក ។

នៅក្នុងខែ ធ្នូ ២០០៨ អង្គការទស្សនៈពិភពលោក បានបញ្ជូនក្រុមយុវជន ក្រុមមិត្តអប់រំមិត្តឱ្យចូលរួមក្នុងកម្មវិធីសមាជពិភពលោកលើកទី ៣ ដើម្បីប្រឆាំងនឹងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ នៅពេលពួកគេត្រឡប់មកវិញ ក្រុមយុវជនបានធ្វើបទបង្ហាញពីអនុសាសន៍របស់ពួកគេទៅកាន់មនុស្សសំខាន់ៗនៅក្នុងប្រទេស ។ នៅក្នុងខែកក្កដា ២០០៩ អង្គការទស្សនៈពិភពលោកកម្ពុជា បានចូលរួមជាមួយគណៈកម្មការបំបាត់ពេស្យាចារ ការរំលោភនិងជួញដូរកុមារនៅកម្ពុជាដើម្បីរៀបចំសិក្ខាសាលាមួយ ក្នុងគោលបំណងចែកចាយព័ត៌មានស្តីអំពីលទ្ធផលសមាជពិភពលោកលើកទី ៣ ។ សម្លេងរបស់យុវជនបានឮសុះសាយដល់ក្រសួងរដ្ឋាភិបាលនានាភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមួយចំនួនដែលធ្វើការដើម្បីការពារកុមារ ។



បន្ថែមលើការផ្តល់អំណាចដល់យុវជននៅក្នុងកម្មវិធីតស៊ូមតិ អង្គការទស្សនៈពិភពលោកកម្ពុជា ក៏បានផ្តល់វគ្គបណ្តុះបណ្តាលតស៊ូមតិទៅដល់ក្រុមសមាជិកសហគមន៍ និងអាជ្ញាធរដែនដីចំនួន ៥៦ នាក់។ បុគ្គលិកធ្វើការជាមួយសហគមន៍ ក៏ត្រូវបានបំពាក់បំប៉នដោយវគ្គតស៊ូមតិដើម្បីឱ្យពួកគេមានសមត្ថភាពថែមទៀតក្នុងការបំពេញភារកិច្ចឆ្លើយតបទៅនឹងបញ្ហាអយុត្តិធម៌នៅក្នុងការងារប្រចាំថ្ងៃ។

ដើម្បីការពារកុមារនៅកម្ពុជាឱ្យប្រសើរឡើង ក្រុមការងារតស៊ូមតិបានចូលរួមយ៉ាងសកម្មក្នុងក្រុមការងាររបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើភាពអយុត្តិធម៌ចំពោះកុមារ។ យើងបានចូលរួម និងសហការយ៉ាងសកម្មជាមួយអង្គការដទៃទៀតដើម្បីជម្រុញឱ្យមានសេចក្តីព្រាងច្បាប់លើការការពារកុមារដែលកំពុងមានភាពចម្រូងចម្រាសជាមួយនឹងច្បាប់ ដោយធ្វើការផ្តល់ជាអនុសាសន៍ផ្សេងៗទៅឱ្យក្រុមការងារក្រសួងដែលធ្វើការលើយុត្តិធម៌របស់កុមារ។ យើងក៏បានសុំឱ្យប្រព័ន្ធយុត្តិធម៌កម្ពុជា បង្កើនការឈឺឆ្អាលថែមទៀតទៅលើកុមារ ដូចជាការធ្វើឱ្យតុលាការផ្តល់នូវបរិយាកាសមេត្រី និងគាំទ្រកក់ក្តៅសម្រាប់កុមារដែលមានចំណែកនៅក្នុងរឿងក្តី។



ដើម្បីពង្រឹងសិទ្ធិមនុស្សនៃប្រជាជនកម្ពុជា ក្រុមតស៊ូមតិបានជួយគាំទ្រដល់ភ្នាក់ងារសិទ្ធិមនុស្ស ដើម្បីរៀបចំខួបលើកទី ៦១ ទិវាសេចក្តីប្រកាសជាសាកលនៃសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្រោមប្រធានបទ "យើងទាំងអស់គ្នាត្រូវការសេរីភាពនៃការបញ្ចេញមតិ និងយុត្តិធម៌" និង "ចូរទទួលយកភាពខុសគ្នា និងបញ្ឈប់ការរើសអើង"។ មានអ្នកចូលរួមចំនួន ៥,000 នាក់ យល់អំពីសិទ្ធិរបស់ពួកគេ ហើយគេរួមគ្នាដើម្បីលើកស្ទួយការណ៍នោះ។

នៅចុងឆ្នាំ ២០០៩ គម្រោងប្រឆាំងការជួញដូរមនុស្សនៃអង្គការទស្សនៈពិភពលោកកម្ពុជាបានចាប់ផ្តើមធ្វើការស្រាវជ្រាវដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីទំហំវប្បធម៌ និងយេនឌ័ររបស់ការចំណាកស្រុក។ យើងចង់ស្វែងយល់ពីសំពាធដែលយុវជនប្រឈមមុខ ជម្រុញឱ្យពួកគេធ្វើចំណាកស្រុក ក៏ដូចជាស្វែងរកកត្តាដែលងាយរងគ្រោះផងដែរ។ ការស្រាវជ្រាវនេះនឹងផ្តល់ព័ត៌មានឱ្យក្រុមការងារតស៊ូមតិអាចធ្វើការតស៊ូមតិដើម្បីឱ្យយើងមានជំហរប្រសើរជាងមុនក្នុងការតស៊ូមតិឱ្យមានគោលនយោបាយដែលអាចធ្វើឱ្យមានការផ្លាស់ប្តូរដល់ជីវិតរបស់យុវជន។

# អ្នកតស៊ូមតិដើម្បីការអភិវឌ្ឍមូលដ្ឋាន



នឿន ហ៊ុន អាយុ ១៨ ឆ្នាំ

" ចង់ឱ្យពួកគេដឹងអំពីសិទ្ធិរបស់ពួកគេ ។ ហើយចង់ឱ្យសហគមន៍របស់ខ្ញុំយល់ដឹងអំពីការអភិវឌ្ឍ ដូច្នេះពួកគេអាចជាចំណែកមួយនៃការអភិវឌ្ឍនេះផងដែរ ។ "

យុវនារីវ័យក្មេង នឿន ហ៊ុន អាយុ ១៨ ឆ្នាំ និងក្រុមយុវជនរបស់នាង បានបញ្ចុះបញ្ចូលក្រុមប្រឹក្សាឃុំ ដើម្បីឱ្យទទួលបានសិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ។

កាលពីមុន ហ៊ុន មិនបានដឹងថានាងមានសិទ្ធិដើម្បីយល់ដឹង ឬអាចចូលរួមក្នុងកិច្ចការងារអភិវឌ្ឍន៍ ដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំនោះឡើយ ។ នាងមិនដឹងថាអ្វីទៅជាអភិបាលកិច្ចមូលដ្ឋាននោះទេ ។ រឿងនេះបានធ្វើឱ្យ ហ៊ុន និងក្រុមយុវជនវ័យក្មេងដទៃទៀតមិនហ៊ានធ្វើសកម្មភាពផ្សេងៗ ដើម្បីជាចំណែកមួយក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាននោះឡើយ ។

បន្ទាប់ពីបានយល់ដឹងពីតួនាទីរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការបណ្តុះបណ្តាលមួយ ក្រោមការឧបត្ថម្ភពីគម្រោងតស៊ូមតិរបស់អង្គការទស្សនៈពិភពលោកកម្ពុជារួចមក ហ៊ុន និងក្រុមយុវជនរបស់នាងបានយកមេរៀនដែលខ្លួនបានរៀនទៅអនុវត្ត ។ រហូតមកដល់ពេលនេះ ហ៊ុន និងក្រុមដ៏សកម្មរបស់នាងបានទទួលការជឿទុកចិត្តពីក្រុមប្រឹក្សាឃុំ ថាជាធនធានដ៏សំខាន់ ។

ហ៊ុន បាននិយាយថា "ខ្ញុំហ៊ានធ្វើការទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ និងហ៊ានសួរសំណួរទៅកាន់ពួកគាត់ ។ យើងបញ្ចុះបញ្ចូលពួកគាត់ឱ្យទទួលស្គាល់ថា បើទោះបីជាយើងនៅក្មេងខ្ចីក៏ដោយ ក៏យើងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបម្រើដល់សហគមន៍របស់ពួកយើងផងដែរ ។"

ខ្ញុំមានមោទនភាពចំពោះខ្លួនឯង ដែលអាចចូលរួមក្នុងការពិភាក្សា និងកិច្ចការងារអភិវឌ្ឍន៍ ។

នាងបន្តទៀតថា "ការចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំគឺមានសារៈសំខាន់ណាស់ ។ វាជួយឱ្យយើងបានដឹងនូវព័ត៌មានពីការងារអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ ។ ហើយខ្ញុំចេះបញ្ចេញមតិយោបល់ និងចេះរៀបចំកិច្ចប្រជុំផងដែរ ។ ឥឡូវនេះ យើងបានកសាងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយពួកគាត់ ។ យើងក៏អាចចូលទៅរកពួកគាត់បានគ្រប់ពេលវេលាផងដែរ ។

ហ៊ុន និងក្រុមយុវជនរបស់នាងមានបំណងផ្តល់ចំណេះដឹងខាងអភិបាលកិច្ចមូលដ្ឋានទៅដល់អ្នកភូមិ សិស្សានុសិស្ស និងយុវជនដទៃទៀត ។

ហ៊ុនបានពន្យល់ថា "ខ្ញុំចង់ឱ្យពួកគេដឹងអំពីសិទ្ធិរបស់ពួកគេ ។ ហើយខ្ញុំចង់ឱ្យសហគមន៍របស់ខ្ញុំយល់ដឹងអំពីការអភិវឌ្ឍ ដូច្នេះពួកគេអាចជាចំណែកមួយនៃការអភិវឌ្ឍនេះផងដែរ ។"



ពួកជំនុំជាដៃគូរបស់អង្គការទស្សនៈពិភពលោកកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល គ្រិស្តបរិស័ទទាំងឡាយ បានប្រឹងប្រែងធ្វើការក្នុងដំណើរការនៃការធ្វើឱ្យសហគមន៍ភ្ញាក់រលឹក ដើម្បីជម្រុញទឹកចិត្តមនុស្សឱ្យចេះសុបិន្តទៅអនាគតដ៏ភ្លឺស្វាងសម្រាប់ពួកគេ។

ប្រធានបទសម្រាប់ឆ្នាំសារពើពន្ធ២០០៩របស់អង្គការទស្សនៈពិភពលោកកម្ពុជាផ្តោតលើ "ការដើរតាមព្រះយេស៊ូគ្រិស្តតាមរយៈការស្វែងរកភាពយុត្តិធម៌" ប្រធានបទខាងលើនេះលើកទឹកចិត្តឱ្យបុគ្គលិកយល់យ៉ាងពេញលេញពីសារៈសំខាន់នៃការប្រឈមមុខអំពើអយុត្តិធម៌ដែលជារបៀបដើម្បីដោះស្រាយបញ្ហាក្រីក្រនៅក្នុងសហគមន៍។

ក្នុងការផ្តួចផ្តើមរបស់ពួកជំនុំជាដៃគូរបស់យើង អង្គការទស្សនៈពិភពលោកធ្វើការជាមួយព្រះវិហារក្នុងមូលដ្ឋានដើម្បីស្វែងរកឱ្យឃើញនូវអត្ថន័យនៃព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ និងរបៀបដែលពួកជំនុំអាចចូលរួមបន្ថែមទៀតជាមួយនឹងបញ្ហាសហគមន៍។តាមរយៈការលើកទឹកចិត្តឱ្យមានសកម្មភាពថែមទៀត ពួកជំនុំ និងសមាជិកពួកជំនុំជាច្រើន គ្រិស្តបរិស័ទនៅមូលដ្ឋានអាចក្លាយជាគំរូ និងស្នបន្ទាល់ល្អដល់អ្នកនៅក្នុងសហគមន៍។ពួកជំនុំក៏អាចជាចំណែកមួយនៃដំណោះស្រាយដើម្បីកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍បានដែរ។ពីមួយពេលទៅមួយពេលអ្នកសម្របសម្រួលកម្មវិធីគ្រិស្តបរិស័ទរៀបចំការបណ្តុះបណ្តាលជាច្រើនដើម្បីពង្រឹងសមត្ថភាព និងការរួបរួមមួយរបស់



# ព័ន្ធកិច្ចគ្រិស្តបរិស័ទ

ឆ្នាំសារពើពន្ធ ២០០៩ គឺជាឆ្នាំល្អសម្រាប់ការសហការ និងភាពជាដៃគូរឹងមាំជាមួយទាំងដៃគូក្នុងមូលដ្ឋាន និងបរទេស ដូចជាអង្គការជះពន្លឺ ទូតសម្រាប់ព្រះគ្រិស្តអន្តរជាតិ កម្មវិធីធីម៉ូថេ ប្រ៊ិយសម្ព័ន្ធកម្ពុជា និងពួកជំនុំគ្រប់គណៈនិកាយនៅក្នុងប្រទេសកម្ពុជា។



ពួកជំនុំមូលដ្ឋាន។ វគ្គបណ្តុះបណ្តាលអ្នកដឹកនាំនៅក្នុងពួកជំនុំមូលដ្ឋាន ធ្វើឱ្យចំណេះដឹងខាងទេវសាស្ត្ររបស់ពួកគេប្រសើរឡើង ដោយព្រោះអ្នកខ្លះមិនមានមធ្យោបាយដើម្បីចូលរៀនសាលាព្រះគម្ពីរនៅក្នុងទីក្រុង។ មានអ្នកដឹកនាំស្ត្រី និងយុវជនបានចូលរួមក្នុងសន្និសិទស្ត្រី និងបោះជំរុំយុវជនដែលរៀបចំឡើងដោយប្រិយសម្ព័ន្ធកម្ពុជា តាមរយៈការគាំទ្រពីពួកជំនុំទាំងឡាយ។ ពួកគេបានទទួលចំណេះដឹងថ្មី និងបានសាងបណ្តាញទំនាក់ទំនងក្នុងចំណោមពួកជំនុំទាំងឡាយនៅក្នុងប្រទេស។ មានការបណ្តុះបណ្តាលគ្រូបង្រៀនថ្ងៃអាទិត្យ បានរៀបចំនៅតាមការិយាល័យប្រតិបត្តិ ដើម្បីបង្កើនសមត្ថភាពគ្រូក្នុងការបង្រៀន និងរៀបចំកុមារឱ្យក្លាយជាភ្នាក់ងារផ្លាស់ប្រែដែលអាចបម្រើសហគមន៍តាមព្រះហរទ័យព្រះ។



ពួកជំនុំដៃគូក្នុងមូលដ្ឋានដែលបានទទួលការបណ្តុះបណ្តាលបំណិនជីវិត បានប្រើចំណេះដឹងរបស់ពួកគេដើម្បីបង្កើនគុណភាពជីវិតសម្រាប់សហគមន៍។ ពួកជំនុំនៅក្នុងតំបន់ប្រតិបត្តិទាំងបួនចាប់ផ្តើមក្រុមសន្សំប្រាក់ដើម្បីជួយដល់សមាជិកក្នុងគ្រាមានអាសន្ន។ ដូច្នេះពួកគេមិនចាំបាច់ពឹងផ្អែកលើការខ្ចីប្រាក់ដែលមានការប្រាក់ខ្ពស់ពីអ្នកចងការលុយទេ។ ការបណ្តុះបណ្តាលខ្លះដែលបានផ្តល់ដល់ពួកជំនុំរួមមាន៖ បញ្ហាសង្គមដូចជាអំពើហិង្សាក្នុងគ្រួសារ ការយល់ដឹងពីយេនឌ័រ ទេសចរណ៍ផ្លូវភេទកុមារ ជំងឺអេដស៍ ការយល់ដឹងពីអ្នកដែលរស់នៅជាមួយនឹងពិការភាព និងមូលដ្ឋានគ្រឹះនៃការតស៊ូមតិ។ ការបណ្តុះបណ្តាលបានផ្តល់ចំណេះដឹងដែលត្រូវការចាំបាច់ដល់សមាជិកពួកជំនុំ។ ពួកគេបានប្រើប្រាស់ធនធានដ៏ស្តួចស្តើងដែលគេមានដើម្បីជួយអ្នករស់នៅជាមួយអេដស៍ តាមរយៈការចែកចាយម្ហូបអាហារជាមូលដ្ឋាន ក៏ដូចជាជួយអធិស្ឋានដល់ពួកគេ។

ពួកជំនុំដៃគូក្នុងមូលដ្ឋានបានចូលរួមជាមួយគ្នា សម្រាប់ការប្រកបគ្រូគង្វាលប្រចាំខែ ជាកន្លែងដែលពួកជំនុំពីនិកាយផ្សេងៗគ្នាអាចចែកចាយការព្រួយបារម្ភរបស់ពួកគេ មេរៀនដែលរៀនបាន និងសំណូមអធិស្ឋានដល់គ្នាទៅវិញទៅមក។ សកម្មភាពបែបនេះបានកសាងទំនាក់ទំនងប្រសើរឡើង និងបង្រួបបង្រួមក្រុមជំនុំពីគណៈនិកាយផ្សេងៗគ្នា។

នៅឯថ្នាក់ជាតិ ពួកជំនុំ និងអ្នកដឹកនាំរបស់ពួកគេក៏បានមករួមគ្នានៅរាល់អាទិត្យទីមួយនៃថ្ងៃព្រហស្បតិ៍ ដើម្បីអធិស្ឋានជាមួយគ្នា។ ក្រុមវេជ្ជបណ្ឌិតគ្រិស្តបរិស័ទក៏បានជួបគ្នារាល់ខែដែរ ដើម្បីពិភាក្សាពីផែនការសកម្មភាព ហើយពួកគេអធិស្ឋានជាមួយគ្នាដើម្បីឱ្យព្រះធ្វើអន្តរាគមន៍ក្នុងការចែកចាយដំណឹងល្អដល់សិស្សពេទ្យ និងបុគ្គលិកនៅមន្ទីរពេទ្យ និងអ្នកជំងឺ។

“ នៅមុនពេលដែលក្លាយជាអ្នកជឿព្រះយេស៊ូវ ខ្ញុំមិនមែនជាមនុស្សល្អទេ ខ្ញុំចូលចិត្តលេងល្បែង និងផឹកស្រា។ រាល់ពេលដែលខ្ញុំស្រវឹង ខ្ញុំបានវាយធ្វើបាបប្រពន្ធ ហើយពេលខ្លះដុតផ្ទះ។ ប្រពន្ធរបស់ខ្ញុំគ្មានសេចក្ដីសុខសាន្តទេ យើងគ្មានសុភមង្គលទេនៅក្នុងគ្រួសារ ហើយខ្ញុំក៏ចេះតែឈឺទៀត។ ”

# ពីអ្នកនេសាទត្រីទៅជា អ្នកនេសាទមនុស្ស



លាង សុវណ្ណា អាយុ ៥៤ ឆ្នាំ
គ្រូគង្វាល

ខ្ញុំបាទឈ្មោះ លាង សុវណ្ណា ហៅថា លាង សុខ ។ ខ្ញុំមានអាយុ ៥៤ ឆ្នាំ ។ ខ្ញុំរស់នៅខេត្តព្រះវិហារ ។ ខ្ញុំបានរៀបការជាមួយប្រពន្ធខ្ញុំឈ្មោះ មាស ខន នៅក្នុងឆ្នាំ ១៩៧៩ ដោយមានកូន ៩ នាក់ (កូនស្រី ៤ និង ប្រុស ៥ នាក់) ។

ជាអកុសល នៅក្នុងឆ្នាំ ១៩៩៧ ប្រពន្ធខ្ញុំបានស្លាប់ចោលខ្ញុំ ដោយសារជំងឺលើសឈាម ។ កូន៧របស់ខ្ញុំ គេធំដឹងក្តីអស់ហើយ ពួកគេក៏បានរៀបការអស់ផងដែរ ។

ក្នុងឆ្នាំ ១៩៩១ ខ្ញុំបានរៀបការម្តងទៀតជាមួយស្ត្រីមេម៉ាយម្នាក់ដែលមានកូនបី ។ ទាំងពីរនាក់យើងមានកូនពីរថែមទៀត ។ ខ្ញុំជាគ្រូគង្វាល ហើយរកស៊ីចិញ្ចឹមជីវិតដោយការនេសាទត្រី ។

នៅមុនពេលដែលខ្ញុំក្លាយជាអ្នកជឿព្រះយេស៊ូវ ខ្ញុំមិនមែនជាមនុស្សល្អទេ ខ្ញុំចូលចិត្តលេងល្បែង និងផឹកស្រា ។ រាល់ពេលដែលខ្ញុំស្រវឹង ខ្ញុំបានវាយធ្វើបាបប្រពន្ធ ហើយពេលខ្លះដុតផ្ទះ ។ ប្រពន្ធរបស់ខ្ញុំគ្មានសេចក្តីសុខសាន្តទេ យើងគ្មានសុភមង្គលទេនៅក្នុងគ្រួសារ ហើយខ្ញុំក៏ចេះតែឈឺទៀត ។

នៅក្នុងឆ្នាំ ២០០២ ព្រះបានសង្គ្រោះជីវិតខ្ញុំតាមរយៈលោកគ្រូគង្វាល ថោង ថាន មកពីព្រះវិហារដំណឹងល្អទាំងបួននៅក្នុងទីរួមខេត្តព្រះវិហារ ។ ជីវិតរបស់ខ្ញុំបានផ្លាស់ប្រែតាំងពីពេលនោះមក ។ ខ្ញុំបានលះបង់ទំលាប់អាក្រក់ចោលទាំងអស់ ។ ប្រពន្ធខ្ញុំ និងកូនរបស់ខ្ញុំបានរស់នៅក្នុងសុភមង្គល ។ បន្ទាប់មក ខ្ញុំ

បានក្លាយជាគ្រូគង្វាល ។ យើងបានរកស៊ីចិញ្ចឹមជីវិតដោយការនេសាទត្រី ។ ទោះបីយ៉ាងណាក៏ដោយ យើងក៏ទទួលការល្បងដ៏ខ្លាំងក្លាពីអ្នកជិតខាងដែលមិនស្គាល់ពីព្រះយេស៊ូវដែរ ។ ពួកគេបានពន្លិចទូកនេសាទរបស់ខ្ញុំ និងម៉ាស៊ីនចូលទៅក្នុងទឹក ប៉ុន្តែសូមសរសើរដល់ព្រះជាម្ចាស់ តាមរយៈការអធិស្ឋាន យើងបានរកឃើញវិញ ។ បន្ទាប់មកគេបានបោះភ្លើងមកលើដំបូងផ្ទះរបស់ខ្ញុំដែលធ្វើពីស្បូវ ប៉ុន្តែដំបូលនោះមិនបានឆេះទេ ពីព្រោះព្រះបានការពារពួកយើង ។ បន្ទាប់មកពួកគេបានកំទេចទូកនេសាទយើងទាំងស្រុងតែម្តង ។ ទោះបីជាពួកគេបានធ្វើអាក្រក់ដល់យើងក៏យើងមិនដែលសងសឹកអ្វីទាំងអស់ ។ ជំនួសឱ្យការសងសឹក យើងនៅតែធ្វើល្អចំពោះគេ ។

តាមរយៈដៃគូជាមួយអង្គការទស្សនៈពិភពលោកកម្ពុជា ខ្ញុំបានទទួលការបណ្តុះបណ្តាលដូចជា: ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ ការដឹកនាំគ្រិស្តបរិស័ទ របៀបថែទាំពួកជំនុំក្នុងមូលដ្ឋាន ជីវិតគ្រួសារគ្រិស្តបរិស័ទ គោលការណ៍មូលដ្ឋានទាំងប្រាំតាមទស្សនៈព្រះគម្ពីរ ការធ្វើជីធម្មជាតិ និងការចិញ្ចឹមមាន់ជាដើម ។ ការបណ្តុះបណ្តាលប្រាកដជាធ្វើឱ្យជំនឿខ្ញុំក្នុងព្រះយេស៊ូវគ្រិស្តរីកចម្រើន ហើយបំភ្លឺឱ្យខ្ញុំយកចិត្តទុកដាក់ដល់អ្នកដទៃជាពិសេសគ្រួសារខ្ញុំ ។ ខ្ញុំព្យាយាមបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ ពីការចិញ្ចឹមសត្វ និងការនេសាទនៅក្នុងទន្លេ ។ ស្ថានភាពគ្រួសារបានប្រសើរឡើង ហើយយើងមានទំនាក់ទំនងល្អជាមួយសមាជិកគ្រួសារទាំងអស់ សុខភាពរបស់យើងក៏ប្រសើរឡើង ពីព្រោះយើងបានបរិភោគទឹកឆ្អិនជាជាងទឹកឆៅពីអណ្តូង និងរស់នៅក្នុងបរិស្ថានស្អាតជាងមុន ។ ខ្ញុំមានចិត្តសម្រាប់សហគមន៍របស់ខ្ញុំ ហើយចង់ជួយពួកគេឱ្យបង្កើនប្រាក់ចំណូលរបស់ពួកគេដូចខ្ញុំដែរ ។

អង្គការទស្សនៈពិភពលោកបានអញ្ជើញខ្ញុំដើម្បីចែកចាយដល់ពួកជំនុំផ្សេងៗទៀតអំពីមេរៀន និងបទពិសោធន៍នៃការជួយសហគមន៍របស់ខ្ញុំ ។ ជាលទ្ធផលពួកជំនុំរបស់ខ្ញុំបានចាប់ផ្តើមគម្រោងតូចមួយនៅផ្ទះដើម្បីជួយឱ្យសមាជិករកបានប្រាក់ចំណូល ។ មនុស្សបានគោរពខ្ញុំ ហើយរាប់ខ្ញុំថាជាអ្នកដឹកនាំ និង គ្រូរបស់គេនៅក្នុងសហគមន៍ ។ ពួកគេចង់អញ្ជើញខ្ញុំធ្វើជាប្រធានអ្នកដឹកនាំសហគមន៍ ។ ខ្ញុំក៏បានសំគាល់ឃើញដែរថាមានការបៀតបៀនតិចជាងមុនពីអ្នកជិតខាង ។ ខ្ញុំអរគុណដល់ព្រះដែលបានប្រើខ្ញុំឱ្យធ្វើជាទីបញ្ចេញពរដល់អ្នកដទៃទៀត ។

ការអប់រំ គឺជាវិស័យមួយក្នុងចំណោមវិស័យចំនួន ៥ ដែលស្ថិតក្នុងយុទ្ធសាស្រ្តថ្នាក់ជាតិរបស់អង្គការទស្សនៈពិភពលោកកម្ពុជាសម្រាប់ឆ្នាំ ២០០៦ ដល់ ២០១០។ ដើម្បីពង្រឹងដល់វិស័យអប់រំក្នុងតំបន់គោលដៅរបស់យើង កម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោកកម្ពុជាបានអនុវត្តគម្រោងចំនួន ៥ និងគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវគុណភាពក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ៣៩។



# កម្មវិធីអប់រំ



**គម្រោងអប់រំបញ្ចូលគ្នា** គឺជាគម្រោងថ្មីស្រឡាងមួយដែលត្រូវបានបង្កើតឡើង ដើម្បីឱ្យមានការចូលរួមកាន់តែប្រសើររបស់កុមារជាជនពិការដើម្បីបញ្ជ្រាបនូវប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជាតាមរយៈការតស៊ូមតិ ការចែករំលែកចំណេះដឹង និងការបង្កើតនូវការអនុវត្តដែលមានការសន្យាសម្រាប់ការបញ្ចូលទៅក្នុងការអប់រំ។

**គម្រោងទប់ស្កាត់កុមាររងាយរងគ្រោះ** បានរៀបចំសិក្ខាសាលារយៈពេល ៣ ថ្ងៃ ស្តីពីកុមារ និងយុវជន ជាភ្នាក់ងារតស៊ូមតិ និងប្រជាធិបតេយ្យក្នុងខេត្តសៀមរាប ដើម្បីធ្វើឱ្យកុមាររាប់រយនាក់អាចយល់ដឹងពីស្ថានភាពទូទៅនៃសង្គមប្រជាធិបតេយ្យ និងតួនាទីរបស់ពួកគេក្នុងអភិបាលកិច្ចមូលដ្ឋាន និងដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍។

**គម្រោងសាលាកុមារមេត្រី** បានធ្វើការជាមួយសាលាបឋមសិក្សាចំនួន ៣ ដើម្បីសម្រេចឱ្យបាននូវអត្រាចុះឈ្មោះចូលរៀនឱ្យបានខ្ពស់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិស្ថានតាមសាលារៀន និងដើម្បីលើកកម្ពស់គុណភាពសិក្សា និងការចូលរួមពីសហគមន៍។

វគ្គអភិវឌ្ឍន៍បុគ្គលិកលក្ខណៈដែលស្ថិតក្រោមគម្រោងផ្តល់ក្តីសង្ឃឹមបានផ្តល់ឱកាសដល់យុវជនជាជនពិការចំនួន ៦០ នាក់ដើម្បីទទួលបាននូវទំនុកចិត្ត។ ពួកគេមានក្តីសង្ឃឹម ក្លាហាន និងចេះចូលរួមក្នុងសង្គម។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះមក យុវជនមួយចំនួនបានទទួលការគាំទ្រដើម្បីឱ្យមានជំនាញច្បាស់លាស់ ហើយមួយចំនួនទៀតបានទទួលការឧបត្ថម្ភដើម្បីបន្តការសិក្សាក្នុងកម្រិតឧត្តមសិក្សា។

ដើម្បីធ្វើឱ្យកុមារដែលរស់នៅក្នុងស្រុករវៀង គូលែន និងត្បែងមានជ័យ ខេត្តព្រះវិហារ អាចទៅសាលារៀន **គម្រោងផ្តល់អាហារូបករណ៍ដល់កុមារី** បានផ្តល់ឱ្យសិស្សានុសិស្ស (ដែលភាគច្រើនជាសិស្សស្រី) ប្រមាណជា ១.២២៨ នាក់នូវកញ្ចប់ស្បៀងអាហារ។



**គម្រោងអប់រំសន្តិភាព** បានធ្វើការដោយសហការណ៍ជាមួយក្រសួងអប់រំយុវជន និងកីឡា ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីសៀវភៅ "វិធីសន្តិភាពសម្រាប់កុមារ"។ អ្នកចូលរួមចំនួន ៣៣ នាក់មកពីការិយាល័យអប់រំយុវជន និងកីឡាខេត្ត នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងនាយកដ្ឋានបឋមសិក្សាក៏បានចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសៀវភៅ "វិធីសន្តិភាពសម្រាប់កុមារ"។

ក្លឹបយុវជន និងកុមារចំនួន ៨៥ ត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ៩។ ប្រធានក្លឹប និងមិត្តអប់រំមិត្ត បានទទួលការបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ អំពើហិង្សាក្នុងគ្រួសារ និងជំនាញសម្របសម្រួល ។ល។ តាមរយៈសៀវភៅវិធីសន្តិភាពសម្រាប់កុមារ ដើម្បីកសាងសមត្ថភាពរបស់ពួកគេ។

**គម្រោងកសាងយុវជនដើម្បីសន្តិភាព** បានដាក់ចេញនូវការកសាងសន្តិភាពនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ៤ របស់អង្គការទស្សនៈពិភពលោកកម្ពុជានៅក្នុងខេត្តព្រះវិហារ ដើម្បីពង្រឹងសមត្ថភាពអ្នកដឹកនាំយុវជន ដើម្បីដឹកនាំយុវជន និងដើម្បីលើកកម្ពស់វប្បធម៌នៃការអានក្នុងចំណោមក្រុមយុវជន។ ឥឡូវនេះមានក្រុមយុវជនចំនួន ៣៦ ដែលមានសមាជិកសរុបចំនួន ៥៨៨ នាក់។ ពួកគេបានដំណើរការបណ្ណាល័យចំនួន ២៥ និងចូលរួមការអភិវឌ្ឍសហគមន៍។

# សន្តិភាពក្នុងចិត្ត



គូ មួង អាយុ ១៥ ឆ្នាំ
ជាប្រធានក្រុមក្លិបវិថីសន្តិភាព

គូ មួង អាយុ ១៥ ឆ្នាំ ជាប្រធានក្រុមក្លិបវិថីសន្តិភាពសម្រាប់កុមារក្នុងអនុវិទ្យាល័យសាមគ្គី ស្ថិតក្នុងស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

គូ មួង បានចូលរួមក្លិបកុមារនេះនៅក្នុងឆ្នាំ ២០០៨ នៅពេលដែលក្លិបនេះត្រូវបានបង្កើតដំបូងនៅក្នុងសាលារៀនរបស់នាងដោយគម្រោងអប់រំសន្តិភាពនៃកម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោកកម្ពុជា ហើយត្រូវបានជ្រើសរើសជាប្រធានក្រុម ។ នាងបានចំណាយពេល ៧ ខែដើម្បីបញ្ចប់វគ្គសិក្សាស្តីពី "វិថីសន្តិភាពសម្រាប់កុមារ" ដែលរៀបចំដោយគម្រោងអប់រំសន្តិភាព ។

ក្រោយពីការបណ្តុះបណ្តាល គូ មួង បានក្លាយជាជនគំរូក្នុងចំណោមមិត្តភក្តិ មិត្តរួមសាលា និងកុមារដែលនៅក្បែរខាងដោយសារតែនាងមានភាពរាក់ទាក់ គួរសម និងដាក់ខ្លួន ។ មុនពេលដែលនាងចូលរួមក្លិប នាងជាក្មេងស្រីម្នាក់ដែលរឹងទទឹង និងមានមោទនភាព ។ នាងមិនស្តាប់ដំបូន្មានឪពុកម្តាយរបស់នាង ហើយក៏មិនដែលចេះសរសើរនរណាម្នាក់ផងដែរ ។ នាងប្រតិកម្មតបតយ៉ាងឆាប់រហ័ស និងដោយឆេវឆាវនៅពេលគេធ្វើឱ្យនាងមិនសប្បាយចិត្ត ។ ជួនកាល ឪពុកម្តាយរបស់នាងបានវាយដំនាង នៅពេលដែលនាងធ្វើឱ្យពួកគេខឹង ជាពិសេសឈ្លោះប្រកែកជាមួយពួកគាត់ ។ ឪពុកម្តាយរបស់នាងស្រែកខ្លាំងដាក់នាងថា "កូនឯងមិនចេះគោរពចាស់ទុំសោះ" ។

គូ មួង ដែលមានអាកប្បកិរិយាខុសប្លែកពីមុន មានភាពក្លាហាន និងរួសរាយ ។ នាងបានយកមេរៀន ដែលនាងបានរៀនទៅអនុវត្ត ។ នាងបានចូលរួមបញ្ឈប់អំពើហិង្សាក្នុងគ្រួសាររបស់នាងដែលជួនកាលមានការទាស់ទែងគ្នា ។

គូ មួង បាននិយាយដោយមោទនភាពថា "ឥឡូវគ្រួសាររបស់ខ្ញុំយល់ដឹងពីផលប៉ះពាល់នៃអំពើហិង្សា ហើយពួកគាត់ស្អប់នូវទង្វើនេះ ។ ខ្ញុំបានបង្រៀនកុមារដែលរស់នៅក្បែរខាងយល់ដឹងពីសិទ្ធិរបស់ពួកគេ និងវិធីដើម្បីកសាងសន្តិភាព ។"

គូ មួង បានធ្វើការរួមគ្នាជាមួយសមាជិកក្លិបរបស់នាង ហើយបានរៀបចំការដើរដង្ហែក្បួនប្រឆាំងបញ្ហាអសកម្មក្នុងសង្គមមួយចំនួន ដូចជា អំពើហិង្សាក្នុងគ្រួសារ ការប្រើហិង្សាក្នុងចំណោមក្មេងជំទង់ ការប្រើប្រាស់គ្រឿងញៀន និងការរំលោភបំពានលើកុមារ ដើម្បីទាក់ទាញការចូលរួមពីអ្នកទាំងឡាយដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះ ។

គូ មួង ដែលជាសិស្សថ្នាក់ទី ៩ ហើយទទួលបានចំណាត់ថ្នាក់លេខ ២ សង្ឃឹមថាសមាជិកសហគមន៍ ជាពិសេសអាជ្ញាធរមូលដ្ឋាន បន្តគាំទ្រក្រុមរបស់នាង ដើម្បីធ្វើកិច្ចការងារសង្គម បើទោះបីជាគម្រោងនេះនឹងបញ្ចប់នៅឆ្នាំក្រោយក៏ដោយ ។



“ ឥឡូវគ្រួសាររបស់ខ្ញុំយល់ដឹងពីផលប៉ះពាល់នៃ
អំពើហិង្សា ហើយពួគាត់ស្អប់នូវទង្វើនេះ។ខ្ញុំបានបង្រៀន
កុមារដែលរស់នៅក្បែរខាងឱ្យយល់ដឹងពីសិទ្ធិរបស់
ពួកគេ និងវិធីដើម្បីកសាងសន្តិភាព។ ”

## កម្មវិធីសន្តិសុខស្បៀង និងទឹក សម្រេចបាននូវសមិទ្ធិផលគួរឱ្យកត់សម្គាល់ជាច្រើន ដើម្បីដោះស្រាយបញ្ហាអសន្តិសុខស្បៀង និងទឹកដល់សហគមន៍ក្រីក្រ និងងាយរងគ្រោះ។

**គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច** បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការកសាងសមត្ថភាពដល់សមាជិកសហគមន៍។ សហគមន៍អភិវឌ្ឍន៍កសិកម្មចំនួន ២ នៅក្នុងស្រុកសំឡូត និងប៉ៃលិនក្នុងខេត្តបាត់ដំបងត្រូវបានបង្កើតឡើង។ ឥឡូវនេះ សហគមន៍អភិវឌ្ឍន៍កសិកម្មស្រុកសំឡូតមានថវិកាជាង ១៩០ លានរៀន (៤៧.៥០០ ដុល្លារ) ហើយសហគមន៍អភិវឌ្ឍន៍ខេត្តប៉ៃលិន មានថវិកាចំនួន ១៣៨ លានរៀន (៣៤.៥០០ដុល្លារ)។

**គម្រោងពង្រឹងសមត្ថភាពសហគមន៍ និងបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន** បានធ្វើដៃគូជាមួយអង្គការ ម៉េក ដើម្បីអនុវត្តន៏ការអប់រំពីគ្រោះថ្នាក់ដោយសារមីន ការសំអាតមីន និងការអភិវឌ្ឍន៏សហគមន៍។ ដីចំនួន ១៥០ ហិកតាត្រូវបានបោសសំអាត។ ការបោសសំអាតនេះបានផ្តល់ប្រយោជន៏ដល់គ្រួសារជាង ៥.៩០០ គ្រួសារដែលរស់នៅក្នុងស្រុករតនមណ្ឌល និងសំឡូត ខេត្តបាត់ដំបង។

**ដោយធ្វើកិច្ចសហប្រតិបត្តិជាមួយមន្ទីររៀបចំដែនដីនគររូបនីយកម្ម និងសំណង់ គម្រោងអប់រំការគ្រប់គ្រងដីធ្លី** បានផ្តល់ការបណ្តុះបណ្តាល និងការយល់ដឹងស្តីពីច្បាប់ភូមិបាលដល់អ្នកភូមិគោលដៅចំនួន ១៦៥ នាក់ ក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ស្រុកគូលែន និងរវៀង ខេត្តព្រះវិហារ។



# កម្មវិធីសន្តិសុខស្បៀង និងទឹក



តាមរយៈគម្រោងកសាងសមត្ថភាពដើម្បីសន្តិសុខស្បៀង និងទឹក អ្នកសម្របសម្រួលគម្រោងនៃកម្មវិធីសន្តិសុខស្បៀង និងទឹក នៅតាមកម្មវិធីអភិវឌ្ឍន៍តំបន់ បានទទួលការកសាងសមត្ថភាព។ អ្នកតំណាងនៅតាមភូមិចំនួន ៦៦ នាក់ ក្នុងស្រុករវៀង និងគូលែននៃខេត្តព្រះវិហារ បានទទួលការបណ្តុះបណ្តាលស្តីពីច្បាប់ភូមិបាល និងបរិស្ថាន។ ដោយសហការណ៍ជាមួយក្រុមប្រឹក្សាឃុំ អ្នកតំណាងនៅតាមភូមិចំនួន ១៩ នាក់ បានធ្វើការបណ្តុះបណ្តាលបន្តស្តីពីច្បាប់ភូមិបាល និងបរិស្ថាន និង ការតស៊ូមតិទៅដល់អ្នកភូមិផ្សេងទៀត។

**គម្រោងផលិតកម្មពពៃ និងទន្សាយ** ត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យការរកប្រាក់ចំណូលមានភាពប្រសើរឡើងដល់ក្រុមយុវជន តាមរយៈការចិញ្ចឹមសត្វ។ យុវជនចំនួន ៤ ក្រុមនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ស្រុករវៀង ខេត្តព្រះវិហារ ត្រូវបានបង្កើតឡើង ហើយបានទទួលការបណ្តុះបណ្តាលពីការចិញ្ចឹមសត្វពពៃ និងទន្សាយ។ ក្រោយពីបណ្តុះបណ្តាលរួចមកក្រុមយុវជនទាំងនោះបានចែករំលែកធនធានផ្ទាល់ខ្លួនរបស់ពួកគេដើម្បីសង់ទ្រុងពពៃ។

**គម្រោងសន្តិសុខស្បៀងប្រចាំគ្រួសារ** ត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យសន្តិសុខស្បៀងអាហារគ្រួសារមានភាពប្រសើរឡើង តាមរយៈការផ្តល់ឱ្យនូវប្រព័ន្ធ និងការគ្រប់គ្រងដី ។ល។ ទៅដល់គ្រួសារក្រីក្រក្នុងភូមិចំនួន ៧ ក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ស្រុកប្រាសាទសម្បូរណ៍ ខេត្តកំពង់ធំ។ គម្រោងបានសម្របសម្រួលបង្កើតកសិករគំរូចំនួន ១៩ នាក់ ដើម្បីផ្លាស់ប្តូរបច្ចេកទេសកសិកម្ម។ សមាគមកសិករចំនួន ៧ ត្រូវបានង្កើតឡើងនៅក្នុងភូមិចំនួន ៧ ដើម្បីគ្រប់គ្រង និងប្រមូលផ្តុំធនធានដែលបានផ្តល់ដោយគម្រោងនេះ។

គម្រោងសន្តិសុខទឹកប្រចាំគ្រួសារបានធ្វើឱ្យប្រសើរឡើងនូវការទទួលបានទឹកទទួលទាន ដែលមានសុវត្ថិភាពដល់គ្រួសារក្រីក្រចំនួន ៧៩២ គ្រួសារនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ អណ្តូងស្នប់ចំនួន ៦៦ និងអាងស្តុកទឹកចំនួន ១៥៥ ត្រូវបានកសាង។ អណ្តូងស្នប់ចំនួន ២ និងអាងស្តុកទឹកចំនួន ៤ នៅតាមសាលារៀនត្រូវបានបំពាក់ ហើយសិស្សានុសិស្សចំនួន ១.៥០០ នាក់ នៃសាលាបឋមសិក្សាចំនួន ៣ អាចទទួលបាននូវទឹកទទួលទានដ៏មានសុវត្ថិភាព។



**ដោយផ្អែកលើគម្រោងគ្រប់គ្រងអនាម័យបរិស្ថានប្រកបដោយនិរន្តរភាព** ការបណ្តុះបណ្តាលចំនួន ៣ វគ្គ ស្តីពីការសំអាតដៃនៅតាមសាលា ត្រូវបានបង្កើតឡើងដើម្បីផ្តល់ឱ្យដល់គ្រូបង្រៀន និងនាយកសាលាចំនួន ៤៥ នាក់មកពីសាលាបឋមសិក្សាចំនួន ៤ ។ សិស្សានុសិស្សចំនួន ២.៣៣០ នាក់ បានយល់ដឹងពីការប្រើប្រាស់ទឹកដែលមានសុវត្ថិភាព និងអនាម័យខ្លួនប្រាណ។

**គម្រោងអនុវត្តអនាម័យ និងទឹកស្អាត** មានគោលដៅដើម្បីពង្រឹងសមត្ថភាពបុគ្គលិកអង្គការទស្សនៈពិភពលោកកម្ពុជា លើការអនុវត្តការសំអាតតាមរយៈដំណើរទស្សនកិច្ចតាមមូលដ្ឋាន និងឯកសារណែនាំពីអនាម័យ និងទឹកស្អាត។ ការបណ្តុះបណ្តាលចំនួន ៣ វគ្គ ស្តីពីការផ្លាស់ប្តូរអនាម័យដែលមានការចូលរួម និងអនាម័យដែលដឹកនាំផ្ទាល់ដោយសហគមន៍ត្រូវបានបង្កើត និងផ្តល់ដល់បុគ្គលិកអង្គការទស្សនៈពិភពលោកកម្ពុជា។

កុមារី ធន់ សុភី អាយុ ១២ ឆ្នាំចំណាយពេលមិនដល់មួយនាទីផង ដើម្បីធ្វើដំណើរទៅកាន់គោលដៅរបស់នាង។ នាងមិនឃើញនរណាម្នាក់ទេនៅទីនោះ។ រំពេចនោះ នាងចាក់ទឹកដែលយកចេញពីអណ្តូងទៅក្នុងធុងទឹកមួយ។

កាលពីមុន សុភី ធ្លាប់ក្រោកតាំងពីព្រហាមដើម្បីទៅយកទឹកមុនទៅសាលារៀន ឬនៅពេលរសៀល បន្ទាប់ពីនាងមកពីសាលារៀនវិញ។

ក្នុងចំណោមបងប្អូនទាំង ៦ នាក់ សុភី គឺជាកូនពៅ ហើយជាញឹកញាប់នាងគឺជាអ្នកទៅយកទឹក។ សុភី ចំណាយពេលពី ១ ម៉ោងទៅ ២ ម៉ោងក្នុងមួយថ្ងៃដើម្បីបំពេញពាងទឹក។

ពេលទៅយកទឹកនាពេលថ្ងៃត្រង់ ជួនកាល សុភី ត្រឡប់មកផ្ទះវិញដោយគ្មានសូម្បីតែទឹកមួយតំណក់ ដោយសារតែមានមនុស្សច្រើនកុះករ។ គ្រួសារជាង ២០០ ក្នុងភូមិតាឡាត់នៃខេត្តកំពង់ឆ្នាំង និងប្រជាជនដទៃទៀតមកពីភូមិក្បែរខាង បានប្រើប្រាស់អណ្តូងនេះដើម្បីយកទឹក។ ទឹកប្រែទៅជាល្អក់នៅពេលដែលមានមនុស្សច្រើនមកដងទឹកពីអណ្តូងនេះ។

សុភី បានរៀបរាប់ថា "ជួនកាល ពួកគេស្រែកដាក់គ្នាថា "ខ្ញុំមកមុនគេ"។ ខ្ញុំមិនបានទឹកទេ ដោយសារមានមនុស្សច្រើនពេកមកយកទឹក។ យើងមិនមានទឹកគ្រប់គ្រាន់ដើម្បីងូត។ វាគួរឱ្យធុញទ្រាន់មែនទែន។"

ជាញឹកញាប់ សុភីឈឺក្បាលដោយសារតែនាងទូលទឹកយ៉ាងធ្ងន់លើក្បាល។ ហើយនាងចុករួយក្បាលជង្គង់ និងសាច់ដុំ។ សុភី មិនមែនជាកុមារតែម្នាក់ទេ ដែលធ្វើការងារបន្ថែមបែបនេះ។ ប៉ុន្តែដោយសារតែមានអណ្តូងទឹកជាច្រើនត្រូវបានសង់ សុភី និងអ្នកភូមិផ្សេងទៀតមិន

## សន្សំពេលវេលា និងកម្លាំង



ធន់ សុភី អាយុ ១២ ឆ្នាំ

“ នៅពេលណាខ្ញុំចង់បានទឹក ខ្ញុំបានភ្លាម។ ខ្ញុំមិនចាំបាច់ដើរឆ្ងាយដើម្បីទៅយកទឹកទេ។ វាជួយខ្ញុំសន្សំពេលវេលា។ ឥឡូវនេះ ខ្ញុំអាចសម្រាក និងយកពេលនេះដើម្បីរៀន។ ”

ចាំបាច់ក្រោកពីព្រលឹមទៅយកទឹកដូចដែលពួកគេធ្លាប់ធ្វើពីមុននោះទេ ។ ហើយពួកគេមិនចាំបាច់ប្រជ្រៀតដើម្បីដណ្តើមគ្នាយកទឹកសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃទេ ។

សុភី និយាយថា "នៅពេលណាខ្ញុំចង់បានទឹកខ្ញុំបានភ្លាម ។ ខ្ញុំមិនចាំបាច់ដើរឆ្ងាយដើម្បីទៅយកទឹកទេ ។ វាជួយខ្ញុំសន្សំពេលវេលា ។ ឥឡូវនេះ ខ្ញុំអាចសម្រាក និងយកពេលនេះដើម្បីរៀន ។"

ឥឡូវនេះ មានអណ្តូងទឹកចំនួន ១៧ ដែលក្នុងនោះអង្គការទស្សនៈពិភពលោកកម្ពុជា បានជួយឧបត្ថម្ភចំនួន ១០ ។ សុភី និងអ្នកភូមិដទៃទៀតលែងព្រួយបារម្ភអំពីការទៅដងទឹកទៀតហើយ ។

សុភី បានឱ្យដឹងថា "ខ្ញុំមានអណ្តូងក្បែរផ្ទះ ។ មិនខ្វះទឹកទៀតទេ ។"



ក្នុងឆ្នាំសារពើពន្ធ ២០០៩ កម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ១១ នៃអង្គការទស្សនៈពិភពលោកកម្ពុជាបានបំពេញនូវកញ្ចប់នៃការអនុវត្ត គម្រោងសុខភាពមាតា និងទារក និងអាហារូបត្ថម្ភ ឬមួយដែលផ្តោតទៅលើរយៈពេលនៃការមានផ្ទៃពោះយ៉ាងសំខាន់ រហូតដល់ ២៤ ខែ ដែលចូលរួមចំណែកដើម្បីឱ្យសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាលើចំណុច ១ , ៤ និង ៥។

កម្មវិធីអភិវឌ្ឍន៏តំបន់ចំនួន ៤ ទៀត បានទទួលនូវដំណើរការកែតម្រូវឡើងវិញ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងកម្មវិធីស្នូលរបស់អង្គការទស្សនៈពិភពលោក។ ការស្រាវជ្រាវលើកដំបូងដែលបានបង្កើតឱ្យមានឡើងនៅជំហានទី ១ នៃកម្មវិធីអភិវឌ្ឍន៏តំបន់ បានជួយជម្រុញដល់ការស្វែងយល់បន្ថែមពីការស្ទង់មតិ ឆ្នាំ ២០០៨ ដោយពាក់ព័ន្ធជាមួយនឹងស្ថានភាពអន់ថយនៃអាហារូបត្ថម្ភរបស់កុមារ ជាពិសេសបញ្ហាកង្វះអាហារូបត្ថម្ភដែលធ្ងន់ធ្ងរ។ វាក៏ជួយបង្កើតបិនឆ្នាកឱ្យកម្មវិធីផងដែរ។ ការកសាងសមត្ថភាពត្រូវបានផ្តល់ឱ្យបុគ្គលិកនៃអង្គការទស្សនៈពិភពលោកកម្ពុជា ដៃគូរដ្ឋាភិបាល និងអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍លើផ្នែកការផ្តល់អាហារបន្ថែមដល់កុមារតូច ការគ្រប់គ្រងទឹកអូរ៉ាលីត និងជាតិស័ង្កសី ដែលជាផ្នែកមួយនៃគម្រោង



## កម្មវិធីសុខភាព និង អាហារូបត្ថម្ភ

សមាហរណកម្ម ការទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារមីក្រូសារជាតិ និងប្រភេទអាហារផ្សេងៗគ្នា។ ឧបករណ៏ទំនាក់ទំនង និងការផ្តល់ប្រឹក្សាត្រូវបានផលិតឡើងដើម្បីផ្គត់ផ្គង់ទៅដល់បុគ្គលិក និងអ្នកស្ម័គ្រចិត្តក្នុងការធ្វើការឱ្យមានការផ្លាស់ប្រែឥរិយាបថនៅតាមគ្រួសារ។ ប្រព័ន្ធតាមដានគ្រប់គ្រងព័ត៌មានកម្មវិធីដ៏ស៊ីជម្រៅ ត្រូវបានវិវត្តន៏តាមរយៈការប្រឹក្សាជាមួយអ្នកពាក់ពន្ធ័គ្រប់ជាន់ថ្នាក់ និងកំពុងត្រូវបានសាកល្បងប្រើប្រាស់មុនពេលយកមកអនុវត្ត។ អង្គការទស្សនៈពិភពលោកកម្ពុជាបានផ្តល់ថ្នាំគ្រាប់ជាតិដែកចំនួន ១៥ លានគ្រាប់ និងថ្នាំជាតិសង្ក័សី ១.៨ លានគ្រាប់ដល់ក្រសួងសុខាភិបាល ដើម្បីបំពេញនូវកង្វះខាតរបស់រដ្ឋាភិបាល។

ការសិក្សាស្រាវជ្រាវទៅលើការកំណត់ និងភាពលើសលប់នៃជំងឺខ្វះឈាមរបស់កុមារមុនអាយុចូលរៀនក្នុង ៤ ខេត្តនៃប្រទេសកម្ពុជាបានចប់សព្វគ្រប់ និងត្រូវបានចែកចាយព័ត៌មានទៅដល់គ្រប់អ្នកពាក់ព័ន្ធសំខាន់ៗ និងនៅក្នុងកិច្ចប្រជុំពិភាក្សាអន្តរជាតិស្តីពីអាហារូបត្ថម្ភឆ្នាំ ២០០៩។ ការសិក្សាបានបង្ហាញថា កម្រិតនៃជំងឺខ្វះឈាមនៅតែបន្តកើនឡើង និងបណ្តាលមកពីការខ្វះជាតិដែកក្នុងចំណោមក្រុមកុមារទាំងនោះ ជាពិសេសគឺក្រុមកុមារដែលមានអាយុតិចជាង ២ឆ្នាំ។ ការវិភាគទៅលើបច្ច័យដែលពាក់ព័ន្ធក្នុងការកំណត់ទៅលើជំងឺខ្វះឈាម គឺមានលក្ខណៈស្មុគ្រស្មាញដោយសារតែការនៅរួមគ្នារវាងគ្រាប់ឈាមក្រហម និងការឆ្លងរោគផ្សេងៗនៅមានកម្រិតខ្ពស់។ គម្រោងមីក្រូសារជាតិនៅខេត្តបាត់ដំបង បានធ្វើការស្រាវជ្រាវដំបូងសម្រាប់ជាការសាកល្បងដោយប្រើប្រាស់ទូរស័ព្ទ ដើម្បីប្រមូលព័ត៌មានស្តីពីអាហារូបត្ថម្ភ។ ការធ្វើការជាដៃគូជាមួយស្រុកប្រតិបត្តិខេត្តបាត់ដំបងដើម្បីធ្វើអន្តរាគមន៍ទៅលើសុខភាព និងអាហារូបត្ថម្ភកុមារតាមរយៈប្រព័ន្ធសុខភាពសាធារណៈ និងតាមអ្នកស្ម័គ្រចិត្តសុខភាពភូមិត្រូវបានធ្វើឡើងដោយជោគជ័យ។



គម្រោងកម្មវិធីធ្វើឱ្យប្រសើរឡើងនូវការគាំពារមាតា និងទារកក្នុងតំបន់គោលដៅក្នុងខេត្តព្រះវិហារ រួមជាមួយការវាយតម្លៃចុងក្រោយដោយអ្នកផ្តល់ប្រឹក្សាដែលមកពីខាងក្រៅ។ការវាយតម្លៃបានបង្ហាញឱ្យឃើញនូវលទ្ធផលរីកចម្រើនជាវិជ្ជមានមួយសម្រាប់សុខភាពមាតានិងទារកដែលទើបនឹងកើត។លទ្ធផលការស្រាវជ្រាវមួយចំនួនបានបង្ហាញថា ការយល់ដឹងពីការថែទាំមុនកំណើត ស្ថាប័នសម្ភព ការថែទាំទារកទើបនឹងកើត ការបំបៅដោះតែមួយមុខ និងការប្រើវិធីសាស្ត្រពន្យាកំណើតមានការកើនឡើងគួរឱ្យកត់សំគាល់។ ការរីកចម្រើនមានកម្រិតខ្ពស់ជាងបើប្រៀបធៀបទៅនឹងតំបន់ដែលបានគ្រប់គ្រង។

ក្នុងឆ្នាំ ២០០៩ កម្មវិធីសុខភាព និងអាហារូបត្ថម្ភបានគាំទ្រដល់ការអនុវត្តគម្រោងសុខភាព និងអាហារូបត្ថម្ភចំនួន ៩ គ្របដណ្តប់ទៅលើ ១៣ កម្មវិធីអភិវឌ្ឍន៍តំបន់ និងមណ្ឌលសុខភាពជាង ៧០។ ថវិកាសម្រាប់គម្រោងសុខភាព និងអាហារូបត្ថម្ភមិនគិតបញ្ចូលគម្រោងសុខភាពដែលឧបត្ថម្ភដោយកម្មវិធីទំនុកបម្រុងមានចំនួនដល់ទៅ ១,៤ លានដុល្លារអាមេរិក។ ថវិកាដែលចំណាយសរុបសម្រាប់ឆ្នាំ ២០០៩ មានចំនួន ១,៦ លានដុល្លារអាមេរិក។ នៅឆ្នាំខាងមុខ កម្មវិធីសុខភាព និងអាហារូបត្ថម្ភ និងបន្តពង្រឹងការរីកចម្រើនក្នុងការធ្វើអន្តរាគមន៍ទៅលើសុខភាពអាហារូបត្ថម្ភមាតា និងទារក និងបន្តការងារអទិភាពរបស់ខ្លួនក្នុងការពង្រឹងគុណភាព និងការឈានទៅមុខនៃការធ្វើអន្តរាគមន៍។

# មណ្ឌលសុខភាពធានាសុវត្ថិភាព ជីវិតរបស់មាតា និងទារក



ខេម ចាន់រី អាយុ ២១ឆ្នាំ

មណ្ឌលសុខភាពក្រាំងល្វាមានទីតាំងនៅ ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ ជារៀងរាល់ព្រឹក មានប្រជាជនជាច្រើនធ្វើដំណើរមកកាន់មណ្ឌលសុខភាពដើម្បីទទួលការព្យាបាល។ ភាគច្រើនអ្នកជំងឺទាំងនោះជាស្ត្រីដែលមានផ្ទៃពោះជាម្តាយ និងកុមារ។ ឥឡូវខុសប្លែកពីមុន ដែលប្រជាជនមិនចូលចិត្តទៅមណ្ឌលសុខភាពនៅខណៈពេលដែលពួកគេឈឺទេ ពីព្រោះគេមិនជឿជាក់ ហើយមណ្ឌលខ្វះឧបករណ៍សម្រាប់ព្យាបាល។ នៅមណ្ឌលសុខភាពមិនមានថ្នាំសម្រាប់ព្យាបាលអ្នកជំងឺទេ។

តែផ្ទុយទៅវិញលោក ជ័យ បាត់ ជាប្រធានមណ្ឌលសុខភាព ក្រាំងល្វា រៀបរាប់ថា ជារៀងរាល់ខែមណ្ឌលទទួលបានអ្នកជំងឺពី ៦០០ ទៅ ៧០០នាក់មកទទួលការផ្តល់ប្រឹក្សាយោបល់ និងព្យាបាល ហើយជាមធ្យមស្ត្រី ២៥ ទៅ ៣០ នាក់មកសម្រាលកូន។

មណ្ឌលសុខភាពអាចផ្តល់ការព្យាបាលគ្រប់ប្រភេទ ដូចជា ជំងឺទូទៅ សម្ភព ការពន្យាកំណើត គម្រោងចាក់វ៉ាក់សាំងការពារថ្នាក់ជាតិ ជំងឺរាករូស ជំងឺរបេង ជំងឺកាមរោគ ជំងឺឃ្លង់ និងការវះកាត់កម្រិតតូច។

ជាមួយគ្នានេះមានគិលានុបដ្ឋាយិកា និងឆ្មបចំនួន ៧ រូប ធ្វើការនៅក្នុងមណ្ឌលនេះ។

អ្នកស្រី ខេម ចាន់រី អាយុ ២១ ឆ្នាំបានឆ្លងទន្លេកូនទីមួយមានមតិថា នាងមានជំនឿ និងមានសុវត្ថិភាពក្នុងការសម្រាលកូននៅក្នុងមណ្ឌលនេះ។ នាងនិយាយទាំងញញឹមថា "ខ្ញុំមានអារម្មណ៍កក់ក្តៅ និងសុវត្ថិភាពពេលឆ្លងទន្លេនៅមណ្ឌលនេះ ពីព្រោះគេមានឧបករណ៍គ្រប់គ្រាន់ និងមានឆ្មបដែលមានជំនាញច្បាស់លាស់។ វាងាយស្រួលណាស់ ពីព្រោះយើងអាចឆ្លងទន្លេនៅមណ្ឌលនេះនៅពេលណាក៏បាន ខ្ញុំសប្បាយចិត្ត និងទទួលនូវសេវាទាំងនេះ។"

អង្គការទស្សនៈពិភពលោក ធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរក្នុងតំបន់ ដើម្បីជួយគាំទ្រមណ្ឌលសុខភាព និងបំពេញតម្រូវការរបស់ប្រជាជនក្នុងសហគមន៍។

> “ ខ្ញុំមានអារម្មណ៍កក់ក្តៅ និងសុវត្ថិភាពពេលឆ្លងទន្លេនៅមណ្ឌលនេះ ពីព្រោះគេមានឧបករណ៍គ្រប់គ្រាន់ និងមានឆ្មបដែលមានជំនាញច្បាស់លាស់។ វាងាយស្រួលណាស់ ពីព្រោះយើងអាចឆ្លងទន្លេនៅមណ្ឌលនេះនៅពេលណាក៏បាន ខ្ញុំសប្បាយចិត្តនឹងទទួលនូវសេវាទាំងនេះ។ ”

តាមលទ្ធផលមណ្ឌលសុខភាពក្រាំងល្វាមានបំពាក់ដោយឧបករណ៍ជំនួយគ្រប់គ្រាន់ ដើម្បីអាចបម្រើឃុំបី (១៣ភូមិ) ដែលមានប្រជាជនចំនួន ១.២៤៥ នាក់។ មានគ្រែពីរសម្រាប់សម្រាលកូន និងគ្រែប្រាំពីរសម្រាប់ជំងឺទូទៅនៅក្នុងនោះរួមមានប្រព័ន្ធទឹក និងម៉ាស៊ីនភ្លើង និងសម្ភារៈសម្រាប់សម្រាលកូនដែលត្រូវបានបំពាក់នៅក្នុងមណ្ឌលដើម្បីឱ្យការងាររលូន និងសុវត្ថិភាព។

ប្រជាជនបានធ្វើការផ្លាស់ប្តូរឥរិយាបថដោយធ្វើដំណើរទៅកាន់មណ្ឌលសុខភាព។ កាលពីមុនគេគិតថាមណ្ឌលសុខភាពជាជម្រើសចុងក្រោយសម្រាប់ទទួលការព្យាបាល ប៉ុន្តែឥឡូវនេះ មណ្ឌលសុខភាពជាជម្រើសទីមួយសម្រាប់ព្យាបាលនៅពេលដែលគេឈឺ។ ទោះបីជាស្ត្រីមានផ្ទៃពោះក៏មានការយល់ឃើញដូច្នេះដែរ។ លោក ជី បាត់ មានស្រាសន៍ថា "ឥឡូវនេះ វាបានក្លាយជារឿងធម្មតាទៅហើយពេលដែលស្ត្រីគាត់បាត់រដូវ គាត់មកមណ្ឌលសុខភាពដើម្បីពិនិត្យមើល ថាតើគាត់មានផ្ទៃពោះ ឬក៏អត់ ដើម្បីទទួលថ្នាំជាតិដែកសម្រាប់សុខភាព និងទារកក្នុងផ្ទៃរបស់គាត់"។

ឆ្លើយតបទៅនឹងសំណួរថា តើទារក ឬម្តាយស្លាប់ពីព្រោះតែការសម្រាលកូនមានញឹកញាប់ដែរឬទេ? លោក ជី បាត់ មានប្រសាសន៍ទាំងញញឹមថា "នៅក្នុងអំឡុងពេលបីឆ្នាំចុងក្រោយនេះគ្មានស្ត្រី ឬទារកណាស្លាប់ដោយសារតែសម្រាលកូនទេ ពីព្រោះតែគេបានយល់អំពីសុខភាព និងពួកគេតែងតែមកពិនិត្យសុខភាពទៀងទាត់។"

មានបណ្តាញយ៉ាងរឹងមាំនៅក្នុងសហគមន៍ដើម្បីលើកស្ទួយការយល់ដឹងពីសុខភាពរបស់ប្រជាជនក្នុងភូមិ។ ក្រុមគាំទ្រសុខភាពក្នុងភូមិ និងអ្នកសម្របសម្រួលដែលមានការផ្លាស់ប្រែ ធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាពីផ្ទះមួយទៅផ្ទះមួយ ដើម្បីផ្តល់ការអប់រំទាក់ទងទៅនឹងសុខភាព ហើយពួកគេយកចិត្តទុកដាក់ចំពោះអ្នកនៅតាមតំបន់ដាច់ស្រយាលមួយដងក្នុងបីខែ ដើម្បីតាមដានបញ្ហាសុខភាព។

ដើម្បីថែទាំមណ្ឌលសុខភាព គេបានគិតតម្លៃចុះឈ្មោះក្នុងតម្លៃទាបបំផុត (១.000 រៀល ឬ ២៥ សេន ដុល្លាសហរដ្ឋអាមេរិក)។ តម្លៃនេះ គឺត្រូវបានសម្រាប់ដោយអ្នកដឹកនាំសហគមន៍ ក៏ប៉ុន្តែគេមិនគិតថ្លៃសម្រាប់ជនក្រីក្រ កុមារកំព្រា និងទាហានរំសាយទេ។



# កម្មវិធីកិច្ចការងារមនុស្សធម៌ និងជំនួយសង្គ្រោះបន្ទាន់



**គម្រោងកាត់បន្ថយគ្រោះមហន្តរាយក្នុងមូលដ្ឋាន នៅតំបន់អភិវឌ្ឍន៍ទាំងពីរបានបញ្ចប់ទៅជាមួយនឹងជ័យជំនះដ៏ធំធេង** - គម្រោងមួយក្នុងចំណោមគម្រោងបីដែលស្វែងរកដើម្បីបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្ថយសញ្ញាគ្រោះមហន្តរាយទៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់បានបញ្ចប់ដោយទទួលបានសមិទ្ធិផលល្អនិងជាមេរៀនសម្រាប់អ្នកដទៃទៀត។គម្រោងគ្រប់គ្រងគ្រោះមហន្តរាយបានអនុវត្តនៅក្នុងតំបន់អភិវឌ្ឍន៍ស្រុកសំរោង និង បរិបូរណ៍។ ការវាយតម្លៃគម្រោងបានបង្ហាញថា

- សមាជិកភាគច្រើននៃគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំបីក្នុងស្រុកសំរោងខេត្តតាកែវនិងឃុំ៦ក្នុងស្រុកសម្បូរណ៍ខេត្តកំពង់ឆ្នាំងបានបង្ហាញការយល់យ៉ាងល្អពីគ្រោះមហន្តរាយក្នុងសហគមន៍របស់គេ និងជឿជាក់ក្នុងការរៀបរាប់ពីរបៀបទាំងឡាយនៃការបន្ថយគ្រោះថ្នាក់។
- ទុនសង្គមកិច្ច (ការទុកចិត្តគ្នា ការសហការ ឆន្ទៈនៃការចែកចាយ ការរួបរួមគ្នា) មានភាពរឹងមាំក្នុងក្រុមជួយខ្លួនឯងរបស់ជនក្រីក្របំផុត និងគ្រួសារងាយរងគ្រោះបំផុត។
- មានការប្តេជ្ញាច្បាស់លាស់ និងមាំមួនចេញពីស្រុកគោលដៅ និងឃុំដើម្បីបន្តបញ្ចូលការបន្ថយគ្រោះមហន្តរាយ និងការរៀបចំគ្រោះមហន្តរាយទៅក្នុងផែនការឃុំប្រចាំឆ្នាំ។ ផែនការគ្រប់គ្រងគ្រោះមហន្តរាយបានត្រូវបញ្ចូលទៅក្នុងថវិកាឃុំប្រចាំឆ្នាំ។

ជាមួយនឹងគម្រោងការកាត់បន្ថយការគ្រប់គ្រងគ្រោះមហន្តរាយអង្គការទស្សនៈពិភពលោកបានអនុវត្តគម្រោងពីរដទៃទៀតលើការគ្រប់គ្រងសញ្ញាគ្រោះថ្នាក់ៈបញ្ជ្រាបការកាត់បន្ថយសញ្ញាគ្រោះមហន្តរាយដែលផ្តល់ថវិកាដោយអង្គការទស្សនៈពិភពលោកកាណាដា និងការរៀបចំសម្រាប់គ្រោះមហន្តរាយហើយគម្រោងកាត់បន្ថយនិងត្រៀមបង្ការគ្រោះមហន្តរាយដែលជួយដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការណ៍អង្គការមិនមែនរដ្ឋាភិបាលក្រោមជំនួយរបស់ទីភ្នាក់ងារអូស្ត្រាលីដើម្បីការអភិវឌ្ឍអន្តរជាតិ។គម្រោងទាំងបីនេះមានកម្មវត្ថុដើម្បីធ្វើឱ្យសមត្ថភាពសហគមន៍ដោះស្រាយជាមួយគ្រោះមហន្តរាយបានដែលនាំដល់ការកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេនិងបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយក្នុងគម្រោងកម្មវិធីអភិវឌ្ឍន៍តំបន់ហើយរដ្ឋាភិបាលមូលដ្ឋាននិងផែនការអភិវឌ្ឍន៍សហគមន៍និងការអនុវត្ត។ គម្រោងនេះបានត្រូវអនុវត្តក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ៩ នៅក្នុងខេត្ត ៥។

រដ្ឋាភិបាលមូលដ្ឋានចំនួន៣០បានចេញរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយដែលហៅថាគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំដែលមានសមាជិក៤០០នាក់ក្នុងឃុំ៣០ក្នុងតំបន់អភិវឌ្ឍន៍៩ក្នុងខេត្តចំនួន ៥ បានត្រូវបំផុស និងបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងចូលដល់សហគមន៍ ហើយនិងធនធានរដ្ឋាភិបាល។

ដើម្បីលើកស្ទួយគ្រួសារនិងសហគមន៍ឱ្យអាចងើបឡើងវិញក្រោយគ្រោះមហន្តរាយសហគមន៍ខ្លះបានចងជាក្រុមរហូតដល់៤៧ជាក្រុមជួយខ្លួនឯងដែលមានសមាជិកប្រហែល៤០០នាក់ជាមួយនឹងប្រាក់សន្សំដែលគេធ្វើដើម្បីបង្កើនប្រាក់ចំណូល និងសម្រាប់ពេលមានអាសន្នផ្សេងៗ។


World Vision
RANGER



## អង្គការទស្សនៈពិភពលោកជួយដល់ជនរងគ្រោះដោយសារខ្យល់ព្យុះកេតសាណា



“ អង្គការទស្សនៈពិភពលោកកម្ពុជា ឆ្លើយតបទៅនឹងទឹកជំនន់ដែលបណ្តាលមកពីខ្យល់ព្យុះកេតសាណា តាមរយៈការធ្វើការយ៉ាងជិតស្និទជាមួយប្រជាជនក្នុងសហគមន៍ និងអាជ្ញាធរដែលនៅតំបន់នោះ ដើម្បីជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា។ មានមនុស្សពេញវ័យ ៦៥៨ នាក់ ( ប្រុស ៣១៤ នាក់ និង ស្រី ៣៤៤នាក់ ) បានទទួលរងគ្រោះដោយសារទឹកជំនន់។ ”

អង្គការទស្សនៈពិភពលោកបានចែកចាយជំនួយឧបត្ថម្ភដល់ប្រជាជនចំនួនប្រាំស្រុកនៅខេត្តសៀមរាប និងកំពង់ធំ។ ស្រុកទាំងនោះមាន ស្រុកជីក្រែង ខេត្តសៀមរាប ស្រុកប្រាសាទបល្ល័ង្គ ស្រុកសណ្តាន់ និងស្រុកស្ទោង។ យើងបានចែកជូនពួកគេនូវគ្រឿងរូបត្ថម្ភសំខាន់ៗ ដូចជា តង់ អង្ករ ត្រីខកំប៉ុង ប្រេងឆា អំបិល ទឹកស្អាតសម្រាប់ទទួលទាន ធុងទឹក មុង សាប៊ូ និងធុងចម្រោះទឹកស្អាត ដោយសរុបជាថវិកាអស់ ១៦.៩១០,៦៧ ដុល្លារសហរដ្ឋអាមេរិក។



កម្មវិធីអេដស៍គ្របដណ្តប់លើខេត្តចំនួនប្រាំបួន រួមទាំងក្រុងភ្នំពេញផង។ មានភូមិចំនួន ៣០០ ដែលគម្រោងរបស់កម្មវិធីអភិវឌ្ឍន៍តំបន់ និងកម្មវិធីតាមផ្នែកកំពុងធ្វើការជាមួយ។

### កុមារងាយរងគ្រោះ និងកុមារកំព្រា (OVC)

ដើម្បីបង្កើនគុណភាពនៃការថែទាំ និងគាំទ្រដល់កុមារងាយរងគ្រោះ និងកុមារកំព្រា កម្មវិធីអេដស៍បានទទួលថវិកាពីអង្គការទស្សនៈពិភពលោកចក្រភពអង់គ្លេស ហុងកុង អូស្ត្រាលី និងមូលនិធិសាកលជុំទីប្រាំពីររួចមកហើយ ដើម្បីដោះស្រាយកង្វះខាតជាមូលដ្ឋានរបស់កុមារងាយរងគ្រោះនិងកុមារកំព្រាដែលមិនទាន់បានជួយ ។មានកុមារ៤.៧៤៦នាក់ដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យរបស់អង្គការទស្សនៈពិភពលោកកម្ពុជាលើភាពងាយរងគ្រោះកំពុងទទួលការថែទាំ និងការការពារពីសហគមន៍ ។

ដើម្បីពង្រឹងសមត្ថភាពរបស់គ្រួសារ ដើម្បីការពារ និង ថែទាំដល់កុមារងាយរងគ្រោះ និងកុមារកំព្រា កម្មវិធីអេដស៍បានចុះស្រាវជ្រាវ និងផ្តល់តម្រូវការខាងម្ហូបអាហារ ការថែទាំសុខភាព សម្ភារៈសិក្សា ទីជម្រក សម្ភារៈប្រើប្រាស់ក្នុងផ្ទះ ប្រាក់កម្ចីសម្រាប់សកម្មភាពបង្កើនប្រាក់ចំណូល និងការជួយខាងផ្នែកចិត្តសាស្ត្រ ហើយនឹងការបណ្តុះបណ្តាលបំណិនជីវិតជាដើម ។ គ្រួសារចំនួន ២.១២៧ ទទួលអាហារឧបត្ថម្ភហើយ ៧៤៩ គ្រួសារ ទទួលបានប្រាក់កម្ចីដើម្បីប្រកបសកម្មភាពបង្កើនប្រាក់ចំណូល ។ ដើម្បីធានាឱ្យរដ្ឋាភិបាលការពារកុមារដែលងាយរងគ្រោះបំផុតតាមរយៈគោលនយោបាយ ផែនការ និងច្បាប់ អង្គការទស្សនៈពិភពលោកបានធ្វើការតស៊ូមតិ និងបង្កើនការយល់ដឹងលើគ្រប់ជាន់ថ្នាក់ ដើម្បីបង្កើតឱ្យមានបរិយាកាសគាំទ្រសម្រាប់កុមារ និងគ្រួសារ ។ វិធីបែបនេះបានសម្រេចចំពោះកុមារនៅក្នុងសាលា ក៏ដូចជាកុមារដទៃទៀតដែលនៅក្នុងសហគមន៍ផងដែរ ។



## កម្មវិធីអេដស៍



## ក្រុមថែទាំតាមផ្ទះ (HBC)

ដើម្បីធ្វើឱ្យអ្នកផ្ទុកមេរោគអេដស៍មានជីវិតធម្មតាឡើងវិញ គម្រោងថែទាំតាមផ្ទះបានផ្តោតលើការជួយដែលមានសកម្មភាពជាច្រើនយ៉ាង ដើម្បីផ្តល់ផលប៉ះពាល់ដល់សន្តិសុខស្បៀង និងស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារអ្នកជំងឺអេដស៍ ។ មានអន្តរាគមន៍ដែលធ្វើឱ្យស្ថានភាពជីវភាពរបស់អ្នកជំងឺ បង្កើនសុខភាពខាងរូបកាយ និងចិត្តសាស្ត្រ និងការបន្ថយអត្រាការស្លាប់របស់អ្នកជំងឺ ។ ដោយមានការគាំទ្រពីអង្គការទស្សនៈពិភពលោកហុងកុង សហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល និងកម្មវិធីស្បៀងអាហារពិភពលោក អង្គការទស្សនៈពិភពលោកមានលទ្ធភាពផ្តល់ស្បៀងជំនួយដល់អ្នកជំងឺអេដស៍ និងគ្រួសាររបស់កុមាររងគ្រោះ និងកុមារកំព្រា ។ កម្មវិធីថែទាំរបស់កម្មវិធីអេដស៍បានធ្វើការជាមួយក្រុមថែទាំតាមផ្ទះ ១៨ ដើម្បីផ្តល់ការថែទាំជាកញ្ចប់គាំទ្រ និងផ្តល់សេវាព្យាបាលដល់អ្នកជំងឺ ២.០៦៨ នាក់ ។ ជាលទ្ធផលអ្នកជំងឺចំនួន ១.៣៣៥ គ្រួសារបានទទួលស្បៀងជំនួយ ៧០% បានទទួលការពន្យាជីវិតហើយបានដំណើរការក្រុមជួយខ្លួនឯងចំនួន ៧១ ក្រុម ។ ដូច្នេះក្នុងឆ្នាំ ២០០៨ នេះអត្រាស្លាប់គឺ ៤% ។ ទោះបីយ៉ាងណាក៏ដោយការរស់នៅជាមួយនឹងអ្នកផ្ទុកមេរោគអេដស៍មិនមែនធម្មតាទេ ហើយការប្រឈមមុខនៅតែមានសម្រាប់កម្មវិធី ដើម្បីធ្វើឱ្យអ្នកជំងឺអេដស៍ត្រឡប់ជាមានជីវិតបង្កើតផលវិញ ។

## ការបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន (PMTCT)

ដើម្បីពង្រឹងសមត្ថភាពសេវាសុខភាពរបស់រដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយការស្លាប់ និងជំងឺរ៉ាំរ៉ៃរបស់ម្តាយ និងកូន អង្គការទស្សនៈពិភពលោកកម្ពុជាគាំទ្រវិធីសាស្ត្របង្ការ ដែលមានសមាសភាពបួនយ៉ាងទាក់ទងទៅនឹងការឆ្លងរោគអេដស៍ដល់ស្ត្រីដែលមានអាយុអាចពរពោះបាន ហើយនិងកូនតូចរបស់ពួកគេដែលហៅថា (PMTCT) ។ ដោយមានជំនួយពីអង្គការទស្សនៈពិភពលោកកាណាដា និងទស្សនៈពិភពលោកហុងកុង មានសេវាកម្មវិធីបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនចំនួន ១១ បានបង្កើតឡើង ។ លើសពីនេះទៀតមានមជ្ឈមណ្ឌលសុខភាពចំនួន ៨០ បានសហការដើម្បីអនុវត្តការបង្ការជំងឺអេដស៍ដំបូង ។ ការបង្ការមេរោគអេដស៍ពីម្តាយទៅកូន បានធ្វើការជាមួយស្ត្រីមានផ្ទៃពោះផ្ទុកចំនួន ៩៩ នាក់ ។ ស្ត្រីចំនួន ៩៤ នាក់ (៩៥%) បានទទួលថ្នាំពន្យា ។ ៩៣% នៃកុមារដែលកើតមកមានផ្ទុកមេរោគអេដស៍ចំនួន ៦៨ នាក់ បានទទួលថ្នាំពន្យាដើម្បីបន្ថយគ្រោះថ្នាក់ផ្ទុកមេរោគ ។ ការបំបៅកូនដោយទឹកដោះសុទ្ធបានទទួលលទ្ធផល ៩៨% ។ វិធីនេះអាចបន្ថយការគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ។

“ ព្រោះតែឪពុករបស់ខ្ញុំស្លាប់ដោយសារជំងឺអេដស៍ គ្រប់គ្នានៅក្នុងភូមិនិយាយដាក់ខ្ញុំថា "អាកើតអេដស៍"។ ខ្ញុំពិតជាអស់សង្ឃឹម និងបាក់ទឹកចិត្ត ខ្ញុំគ្មានមិត្តភក្តិច្រើនទេ ហើយគ្រប់គ្នាហាក់បីដូចជារើសអើងខ្ញុំ ព្រមទាំងក្រុមគ្រួសាររបស់ខ្ញុំ។ ”



វិបុល អាយុ ១២ ឆ្នាំ
ដែលបានក្លាយជាកុមារកំព្រា
ដោយសារតែជំងឺអេដស៍

# សូមកុំនាំអេដស៍ចូលផ្ទះ

កុមារា វិបុល បាននិយាយទាំងទឹកភ្នែកថា "សូមកុំនាំអេដស៍ចូលផ្ទះ"។ កុមារាអាយុ ១២ ឆ្នាំ ដែលបានក្លាយជាកុមារកំព្រាដោយសារតែជំងឺអេដស៍។ វិបុលរស់នៅភាគខាងជើងនៃប្រទេសកម្ពុជាដែលឆ្ងាយពីក្រុងភ្នំពេញ ១៦៨ គីឡូម៉ែត្រ។ ឪពុករបស់ វិបុល ឈ្មោះ សូផាន ដែលបានឆ្លងមេរោគអេដស៍ និងស្លាប់ដោយសារជំងឺអេដស៍។ វិបុលបានចែកចាយដោយក្រៀមក្រំថា" ខ្ញុំនឹកឪពុករបស់ខ្ញុំណាស់។ សព្វថ្ងៃនេះ ខ្ញុំរស់នៅជាមួយអ៊ំស្រីរបស់ខ្ញុំ និងកូនៗទាំង ៥ របស់គាត់។ គាត់ល្អចំពោះខ្ញុំ និងប្អូនប្រុសរបស់ខ្ញុំឈ្មោះ វីរៈ អាយុ ១០ ឆ្នាំ។" កុមារា វិបុល មិនអាចទប់ទឹកភ្នែកបាននៅពេលដែលកុមាររាយរ៉ាប់រឿងរ៉ាវជីវិតរបស់កុមារ។ វិបុល មិនត្រឹមតែបាត់បង់ឪពុកប៉ុណ្ណោះទេ ថែមទាំងបាត់បង់ម្តាយ ដែលគាត់បានរត់ចោលកូនៗដោយមិននិយាយអ្វីទាំងអស់។ គាត់យំរៀបរាប់ថា "ប្អូនប្រុសរបស់ខ្ញុំ និងខ្ញុំបានក្លាយជា ក្មេងកំព្រា ហើយជាអ្នកងាយរងគ្រោះដោយសារតែជំងឺ អេដស៍"។ សំណាងល្អកុមារា វិបុល និង វីរៈ មិនមានមេរោគអេដស៍ទេ។ វិបុលបានយំរៀបរាប់ថា"ដោយសារតែឪពុករបស់ខ្ញុំស្លាប់ដោយសារជំងឺអេដស៍ ដូច្នេះហើយ គ្រប់គ្នានៅក្នុងភូមិនិយាយដាក់ខ្ញុំថា"អាកើតអេដស៍"។ ខ្ញុំពិតជាគ្មានកំលាំងចិត្ត និងគ្មានការលើកទឹកចិត្តសោះ ខ្ញុំមិនមានមិត្តភ័ក្តិច្រើនទេ ហើយគ្រប់គ្នាហាក់បីដូចជារើសអើងរូបខ្ញុំ ព្រមទាំងក្រុមគ្រួសាររបស់ខ្ញុំ។" ដោយសារតែជីវភាពយ៉ាប់យ៉ឺនពេកម្តាយរបស់ វិបុល បានចាកចោលផ្ទះទុកឱ្យកូនៗ រស់នៅជាមួយនឹងជីដូនចាស់។ រយៈពេលពីរ-បីឆ្នាំក្រោយមក ដោយសារជរាពាធ ជីដូនបានទទួលមរណៈភាព ដូច្នេះកុមារទាំងពីរនាក់បងប្អូនត្រូវបានសង្គ្រោះយកទៅចិញ្ចឹមដោយអ៊ំស្រីរបស់គេឈ្មោះ បុប្ផា អាយុ ៣៥ ឆ្នាំដែលប្រកបមុខរបរដាំបន្លែបន្តិចបន្តួច"នៅផ្ទះ និងលក់ផ្លែក្រូច ដើររកចំណូលមកផ្គត់ផ្គង់ជីវភាព។ វិបុល បានយំខ្សឹបខ្សួល និងរៀបរាប់ថា "ជីវភាពគ្រួសាររបស់ខ្ញុំពិតជាក្រីក្រ ហើយញាតិជិតខាងហាក់ដូចជាស្អប់ពួកយើងខ្លាំងណាស់។ មានពេលខ្លះក្រុមគ្រួសារខ្ញុំអត់មានអីញ៉ាំ យើងញ៉ាំតែបបរសហើយស្លៀកពាក់សំលៀកបំពាក់ចាស់ៗ។ ខ្ញុំតែងតែខិតខំព្យាយាមរៀនសូត្រ។"

ក្នុងឆ្នាំ ២០០៦ កុមារា វិបុល បានចូលក្នុងគម្រោងកុមារកំព្រាងាយរងគ្រោះរបស់អង្គការទស្សនៈពិភពលោក ។ ជីវិតរបស់វិបុល មានការផ្លាស់ប្រែដោយសារតែមានការផ្តល់កំលាំងចិត្ត និងការផ្គត់ផ្គង់ផ្សេងៗ ពីអង្គការទស្សនៈពិភពលោក ជាមួយគ្នានេះដែរសហគមន៏ឈប់រើសអើងក្រុមគ្រួសាររបស់ វិបុល ដោយសារសហគមន៏យល់ដឹងច្រើនពីមេរោគអេដស៏ និងអេដស៏ និងដឹងពីស្ថានភាពក្រុមគ្រួសាររបស់ វិបុល ។

គម្រោងកុមារកំព្រានិងកុមារងាយរងគ្រោះនៃអង្គការទស្សនៈពិភពលោកព្យាយាមបង្កើនសមត្ថភាពដល់សហគមន៏ក្នុងការការពារកុមារពីគ្រោះថ្នាក់នៃការធ្វើអាជីវកម្មលើកុមារ ផ្តល់ការថែទាំនិងគាំទ្រដល់កុមារកំព្រា និងកុមារងាយរងគ្រោះ និងធ្វើឱ្យប្រាកដថាពួកគេអាចចូលរៀននៅសាលារដ្ឋ ទទួលការថែទាំផ្នែកសុខភាព រៀនវិជ្ជាជីវៈ និងវិស័យដទៃផ្សេងទៀត ។

វិបុល ជាមួយទឹកភ្នែកយំខ្សឹបខ្សួលបាននិយាយថា "សូមឪពុកម្តាយទាំងអស់ថែរក្សាកូនៗ ឱ្យបានល្អ ។គ្រប់ឪពុកទាំងអស់សូមកុំយកអេដស៏ចូលផ្ទះ ។" កុមារាបានបន្ថែមទៀតដោយញញឹមទាំងទឹកភ្នែកថា "ពេលនេះខ្ញុំមានមិត្តភ័ក្រ្តច្រើន ហើយអ្នកភូមិគាត់ឈប់រើសអើងក្រុមគ្រួសារខ្ញុំហើយ ។ ខ្ញុំពិតជារីករាយជាមួយនឹងអ្វីដែលផ្លាស់ប្រែក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំមានអាហារញាំគ្រប់គ្រាន់ ខ្ញុំមានបុគ្គលិកអង្គការទស្សនៈពិភពលោក ដែលតែងតែលើកទឹកចិត្ត និងផ្តល់ការលើកទឹកចិត្ត ដែលជាការលើកទឹកចិត្តដ៏សំខាន់សម្រាប់ជីវិតរបស់យើង ។ ខ្ញុំនឹងខិតខំព្យាយាមរៀនសូត្រ ក្តីស្រម៉ៃរបស់ខ្ញុំ ខ្ញុំចង់ក្លាយទៅជាគ្រូបង្រៀនម្នាក់នៅក្នុងសហគមន៏ ហើយខ្ញុំនឹងទទួលបាននូវការគោរពផងដែរ ។ ខ្ញុំទទួលបានកង់មួយគ្រឿងពីអង្គការទស្សនៈពិភពលោក ខ្ញុំជិះកង់នេះទៅសាលារៀនជំនួសការដើរទៅសាលា ។ សាលារៀនរបស់ខ្ញុំនៅឆ្ងាយពីផ្ទះ ។ វិបុល និងអ៊ំស្រីរបស់កុមារបាននិយាយថា "យើងសូមអរគុណអង្គការទស្សនៈពិភពលោកដែលបានសង្គ្រោះជីវិតរបស់ពួកយើង ហើយគ្រប់ៗគ្នាក៏ឈប់រើសអើងពួកយើង ។ ពួកគេយល់ដឹងពីស្ថានភាព និងផ្គត់ផ្គង់យើង ។" អ៊ំស្រីរបស់ វិបុល បានចែកចាយថា "វិបុល ជាក្មេងឧស្សាហ៏ គេចេះដាំបាយ បោកសំលៀកបំពាក់ បោសជូតផ្ទះ និងរៀបចំកន្ទេលខ្នើយកន្លែងគេងរាល់យប់ដោយខ្លួនគេផ្ទាល់ ។ គេជួយបង្ហាត់ប្អូនៗរបស់គេឱ្យចេះអាន និងចេះសរសេរ ។"



*កំណត់សំគាល់: ឈ្មោះរបស់កុមារា និងឈ្មោះទាំងអស់ដែលមាននៅក្នុងសាច់រឿងនេះត្រូវបានប្តូរ ដោយសារនេះជារឿងរបស់កុមារដែលងាយរងគ្រោះ ។ ដើម្បីសុវត្ថិភាព យើងសូមរក្សានូវអត្តសញ្ញាណរបស់កុមារ ។*

កម្មវិធីសន្តិភាព និងយុត្តិធម៌ស្វែងរកឱ្យមានការផ្លាស់ប្រែតាមរយៈការសហការគ្នាជាមួយសហគមន៍ ប៉ូលីសកម្ពុជាប្រឆាំងការជួញដូរមនុស្សថ្នាក់ជាតិ និងកុមារដើម្បីនិយាយពីបញ្ហាយុត្តិធម៌សម្រាប់កុមារ។



# កម្មវិធីសន្តិភាព និង យុត្តិធម៌

កម្មវិធីសន្តិភាព និងយុត្តិធម៌ ស្វែងរកឱ្យមានការផ្លាស់ប្រែតាមរយៈការសហការគ្នាជាមួយសហគមន៍ ប៉ូលីសកម្ពុជាប្រឆាំងការជួញដូរមនុស្សថ្នាក់ជាតិ និងកុមារ ដើម្បីនិយាយពីបញ្ហាយុត្តិធម៌សម្រាប់កុមារ។ មានគម្រោងជាច្រើននៅក្នុងកម្មវិធីនេះដែលស្វះស្វែងដើម្បីការពារ និងយកចិត្តទុកដាក់ដល់កុមារ ក៏ដូចជាធ្វើការបង្ការកុមារកុំឱ្យធ្លាក់ជាជនរងគ្រោះពីសំណាក់ការរំលោភបំពានតាមទម្រង់ជាច្រើន។ នៅក្នុងឆ្នាំសារពើពន្ធ ២០០៩ គម្រោងសុវត្ថិភាពទេសចរណ៍ដល់កុមាររបស់កម្មវិធីសន្តិភាព និងយុត្តិធម៌ បានត្រូវបញ្ចប់ បន្ទាប់ពីដំណើរការអស់រយៈពេលបីឆ្នាំមក។ គម្រោងនេះបានសហការជាមួយអ្នកជំនាញទេសចរណ៍ និងស្ទង់ការសុវត្ថិភាពទេសចរណ៍សម្រាប់កុមារថ្នាក់ខេត្តរបស់រដ្ឋាភិបាល ដើម្បីធានាឱ្យសារអំពីការការពារកុមារ បានទៅដល់ទីដាច់ស្រយាលនៃប្រទេសកម្ពុជា។

អង្គការទស្សនៈពិភពលោកបន្តធ្វើជាដៃគូជាមួយនឹងការពង្រឹងច្បាប់ ដើម្បីធានាឱ្យមានបណ្តាញទាក់ទងទាន់ហេតុការណ៍ថ្នាក់ជាតិ និងការឆ្លើយតបកើតឡើង។ កម្មវិធីបានចាប់ដៃគូជាមួយកុមារ គ្រួសាររបស់គេ និងសហគមន៍ ដើម្បីជួយដល់ពួកអ្នកដែលរស់នៅក្នុងកាលៈទេសៈលំបាក និងអ្នកដែលកំពុងឆ្លងកាត់វិបត្តិ។ បុគ្គលិក និងដៃគូបានឈោងចាប់ដល់ពួកកុមារអនាថាដែលនៅតាមផ្លូវ ផ្តល់កន្លែងមានសុវត្ថិភាពដល់អ្នកដែលរស់នៅតាមថ្នល់ ក៏ដូចជាអ្នកដែលរស់នៅក្នុងផ្ទះបណ្តោះអាសន្ននូវការការពារ យកចិត្តទុកដាក់ និងផ្តល់ការពិគ្រោះយោបល់ខាងមនោសញ្ចេតនាសម្រាប់កុមារដែលបានទទួលការរំលោភបំពាន។ ក្នុងឆ្នាំ ២០០៩ គម្រោងការបំផ្លាស់បំប្រែកុមារតាមថ្នល់បានឈោងដល់ និងប្រាស្រ័យទាក់ទងកុមារចំនួន ៥.៣១១នាក់ ហើយក៏បានផ្តល់អំណាចដល់គេតាមរយៈការរៀនក្រៅប្រព័ន្ធអំពីជីវិត។ កុមារចំនួន ៣៥នាក់ បានសម្រេចចិត្តស្នាក់នៅក្នុងមណ្ឌលរហូតដល់គេអាចចូលរៀនក្នុងសាលារដ្ឋបាន ហើយថ្ងៃមួយគេនឹងអាចចូលរៀនតាមជំនាញដែលគេចូលចិត្ត។ កុមារនៅក្នុងកាលៈទេសៈលំបាកបានត្រូវផ្តល់អំណាចនៅឆ្នាំ ២០០៩ នេះតាមរយៈក្មេងស្រី ១៦ នាក់ដែលបានឈ្នះក្តីនៅតុលាការ ហើយអាចនាំអ្នករំលោភពួកគេទៅកាត់ទោស ដោយមានការជួយឧបត្ថម្ភពីអង្គការទស្សនៈពិភពលោក និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ។ កុមារខ្លះដែលត្រូវបានគេលក់ និងរំលោភ បានទទួលសេរីភាពរបស់គេវិញតាមរយៈវគ្គបណ្តុះបណ្តាលជំនាញថ្មី និងចាប់ផ្តើមមុខរបរផ្ទាល់ខ្លួនរបស់ពួកគេ។

ស្របគ្នានឹងការការពារកុមារ កម្មវិធីសន្តិភាព និងយុត្តិធម៌ក៏បានធ្វើការដើម្បីបញ្ឈប់ការកេងប្រវ័ញ្ចកំលាំងរបស់កុមារដែរ។ យើងបានធ្វើជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុកឈ្មោះថា លីកាដូ និងអាដ្ហាធរ ដើម្បីរៀបចំព្រឹត្តិការណ៍ជាតិបីលើក ដែលមានអ្នកចូលរួមរហូតដល់ ១០.០០០នាក់ ដើម្បីនឹងចែកចាយសារអំពីបរិស្ថានការងារសុវត្ថិភាព ក៏ដូចជាសិទ្ធិកុមារ ដែលកំពុងធ្វើការផង ទៅរៀនផង ទទួលគាំពារសុខភាព និងការការពារផុតពីការងារកេងប្រវ័ញ្ច។

គម្រោងបានទាក់ទងជាមួយនឹងកុមារចំនួន ១.៩៥៨នាក់ ហើយ ១១២នាក់ បានបញ្ជូនទៅមណ្ឌលផ្សេងៗជាកន្លែង ដែលពួកគេបានទទួលការអប់រំក្រៅប្រព័ន្ធ។ គម្រោងក៏ជួយសម្របសម្រួលការធ្វើសមាហរណកម្មដែរ ដែលកុមារ ២៨នាក់ បានចូលសាលាវិញ ហើយ ៤0នាក់ អាចត្រឡប់ទៅរួបរួមជាមួយគ្រួសារគេវិញ។

តាមរយៈការបណ្តុះបណ្តាល ការផ្សព្វផ្សាយការយល់ដឹង និងការសហការយ៉ាងរឹងមាំជាមួយសហគមន៍ អាជ្ញាធរ និងអង្គការមូលដ្ឋានដទៃទៀត កម្មវិធីសន្តិភាព និងយុត្តិធម៌របស់អង្គការទស្សនៈពិភពលោកបានបន្តធ្វើការឆ្ពោះទៅរកគោលដៅនៃការកសាងពិភពលោកមួយប្រសើរឡើងសម្រាប់ជីវិតកុមារ ដើម្បីធានាឱ្យពួកគេមានជីវិតពេញបរិបូរណ៍សម្រាប់កុមារកម្ពុជាទាំងអស់។



ង៉ន ជាក្មេងស្រីជនជាតិវៀតណាមដែលមានអាយុ ១៦ ឆ្នាំ។ នាងបានរស់នៅជាមួយឪពុកម្តាយរបស់នាងនៅខេត្តសៀមរាប។ នាងជាកូនស្រីតែម្នាក់គត់នៅក្នុងចំណោមបងប្អូនបួននាក់។ ឪពុករបស់នាងមានជំងឺជាទម្ងន់ដោយសារគាត់មានជំងឺថ្លើម។ ម្តាយរបស់នាងប្រកបរបរលក់ម្ហូបអាហារ ដើម្បីចិញ្ចឹមគ្រួសារ។ ង៉ន ពិតជាចង់ធ្វើអ្វីមួយដើម្បីជួយក្រុមគ្រួសារ។

មិត្តរបស់ ង៉ន បានបបួល ង៉នទៅធ្វើការជាអ្នកបំរើតុនៅក្នុងហាងកាហ្វេសេដ្ឋីបុត្រមួយ នៅពេលនោះ ង៉នទើបតែមានអាយុ ១៥ ឆ្នាំប៉ុណ្ណោះ។ តាមការពិតហាងនោះមានលក្ខណៈដូចជាផ្ទះបនដែរ។

វាជាពេលដែល ង៉ន ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ម្តាយនាង។ ឪពុករបស់នាងមិនអាចធ្វើការងារទៀតទេ។ ម្តាយរបស់នាងមានផ្ទៃពោះ និងចាញ់ទារកក្នុងផ្ទៃ ដូច្នេះគាត់មិនអាចរកទទួលទានបានទេ។

ក្រោយពីបានបញ្ចុះបញ្ចូលជាច្រើនលើកច្រើនសារ ម្តាយរបស់ ង៉ន ក៏បានអនុញ្ញាតឱ្យនាងធ្វើការនៅទីនោះ។

ង៉ន ត្រូវធ្វើការពីម៉ោង ៧ យប់ដល់ម៉ោង ៩ ព្រឹក។ ថ្ងៃមួយមានបុរសម្នាក់ដើរសំដៅមកនាង និងសុំឱ្យនាងរួមភេទជាមួយគេ។

ង៉ន មានការរន្ធត់យ៉ាងខ្លាំង ក៏ប៉ុន្តែដោយសារតែត្រូវការប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសារនាងក៏សម្រេចធ្វើតាម។

ង៉ន  អាចរកប្រាក់បានពី ១០ ទៅ ១៥០ ដុល្លារក្នុងភ្ញៀវម្នាក់ ប៉ុន្តែនាងត្រូវបង់ប្រាក់ចំណូលរបស់នាងពាក់កណ្តាលទៅម្ចាស់ហាង។ ធ្វើការនៅក្នុងពេស្យាស្ថានមិនមែនជារឿងងាយស្រួលនោះទេ។ ង៉ន បាននិយាយថា "ខ្ញុំមានការលំបាកយ៉ាងខ្លាំងនៅពេលណាដែលភ្ញៀវគាត់ស្រវឹងស្រា។ មានភ្ញៀវខ្លះមិនឱ្យប្រាក់ខ្ញុំទេ ក្រោយពីខ្ញុំបម្រើសេវាឱ្យគាត់ ប៉ុន្តែខ្ញុំត្រូវតែបង់ប្រាក់ឱ្យម្ចាស់ហាងចំពោះគ្រប់ភ្ញៀវ។ នៅពេលដែលខ្ញុំឈឺ និងអស់កម្លាំងម្ចាស់ហាងមិនឱ្យខ្ញុំឈប់សម្រាកទេ។"



ង៉ន អាយុ ១៦ឆ្នាំ ជនជាតិវៀតណាម

## រកឃើញកន្លែងចាប់ផ្តើមជីវិតថ្មី

“ រស់នៅក្នុងមជ្ឈមណ្ឌលនេះ មានអ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការ ដូចជាទីកន្លែងស្នាក់នៅ អាហារឆ្ងាញ់សម្រាប់បរិភោគ សំលៀកបំពាក់សមរម្យសម្រាប់ស្លៀកពាក់។ មិនតែប៉ុណ្ណោះខ្ញុំមានឱកាសរៀនភាសាអង់គ្លេស និងភាសាខ្មែរ ហើយខ្ញុំអាចរៀនជំនាញកាត់ដេរផងដែរ។ ”

ក្រៅពីរកប្រាក់ចិញ្ចឹមគ្រួសារ ង៉ន ក៏មានការស្រមើស្រម៉ៃមួយគឺ "កាលខ្ញុំនៅក្មេង ខ្ញុំចង់មានហាងសំអាងការមួយ នេះជាមូលហេតុដែលខ្ញុំសម្រេចចិត្តយកមុខរបរជាអ្នករកស៊ីផ្លូវភេទ ដូច្នេះខ្ញុំអាចសន្សំប្រាក់ខ្លះដើម្បីបើកហាង ។" មួយឆ្នាំក្រោយមក ង៉ន ក៏ត្រូវបានប៉ូលិសចាប់រួចបញ្ជូនទៅមជ្ឈមណ្ឌលនារាថ្មីរបស់អង្គការទស្សនៈពិភពលោកនៅ ខែមិថុនា ឆ្នាំ ២០០៩ ។

ង៉ន បាននិយាយទាំងទឹកមុខស្មោះត្រង់ថា "រស់នៅក្នុងមជ្ឈមណ្ឌលនេះមានអ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការដូចជាទីកន្លែងស្នាក់នៅ អាហារឆ្ងាញ់សម្រាប់បរិភោគសំលៀកបំពាក់សមរម្យសម្រាប់ស្លៀកពាក់ ។ មិនតែប៉ុណ្ណោះខ្ញុំមានឱកាសរៀនភាសាអង់គ្លេស និងភាសាខ្មែរ ហើយខ្ញុំអាចរៀនជំនាញកាត់ដេរផងដែរ ។"

ក្រៅពីទទួលការថែទាំផ្នែករាង្គកាយ ង៉ន បានទទួលការគាំទ្រផ្នែកអារម្មណ៍ពីម្តាយ ( អ្នកផ្តល់ប្រឹក្សា) នៅក្នុងមណ្ឌលទៀតផង ។ ពួកគេបានលើកទឹកចិត្តឱ្យនាងរស់នៅក្នុងជីវិតថ្មី និងអនុញ្ញាតឱ្យនាងទៅកំសាន្តនៅកន្លែងប្លែកៗ និងទៅលេងផ្ទះទៀតផង ។ ម្តាយរបស់នាងក៏ធ្លាប់ទៅសួរសុខទុក្ខនាងនៅមជ្ឈមណ្ឌលដែរ ។

ង៉ន បានសម្រេចចិត្តមិនវិលត្រឡប់ទៅជីវិតចាស់នាងកាលពីមុនទៀតទេ នាងប្រាថ្នាមានការងារផ្សេងនៅថ្ងៃអនាគត ។ នាងនិយាយដោយទន់ភ្លន់ និងមានការតាំងចិត្តយ៉ាងរឹងមាំថា "បន្ទាប់ពីចាកចេញពីមជ្ឈមណ្ឌល ខ្ញុំចង់បើកហាងតូចមួយដើម្បីលក់ទឹកក្រឡុក បបរ ឬបាយ និងកាហ្វេ ។"

តាមរយៈបទពិសោធន៏របស់នាង ង៉ន ក៏បានដាស់តឿនក្មេងៗស្រីជំនាន់ក្រោយដទៃទៀតកុំធ្វើតម្រាប់តាមនាង ។ នាងបាននិយាយថា "ខ្ញុំចង់និយាយទៅកាន់ក្មេងស្រីដទៃទៀតកុំធ្វើតាមខ្ញុំ ។ ការងារនេះមិនល្អទេសម្រាប់ក្មេងស្រី ពួកគេគួរតែស្វែងរកការងារណាដែលប្រសើរជាងនេះ ។"

*កំណត់សំគាល់: ឈ្មោះរបស់កុមារីនៅក្នុងសាច់រឿងនេះត្រូវបានប្តូរ ដោយសារនេះជារឿងរបស់កុមាររងាយរងគ្រោះ ។ ដើម្បីសុវត្ថិភាព យើងសូមរក្សានូវអត្តសញ្ញាណរបស់កុមារ ។*



## ប្រតិបត្តិការ

ក្រុមហ៊ុនវីសិនហ្វាន់-កម្ពុជា បានបម្រើគ្រួសារក្រីក្រចំនួន ៩៤.៥00 ជាមួយនឹងផលប័ត្រឥណទានប្រមាណជិត ២0 លានដុល្លា។ ក្រុមហ៊ុនបានពង្រីកខ្លួនដល់ស្រុកថ្មីចំនួន ១៧ នៅក្នុងខេត្តក្រុងទាំង១៣ រួមទាំងកម្មវិធីអភិវឌ្ឍន៍តំបន់ទាំង ៣៩ កន្លែង។ វីសិនហ្វាន់ ជាក្រុមហ៊ុនទីមួយដែលបានធ្វើសវនកម្មអំពីផលប៉ះពាល់ផ្នែកសង្គម ដោយស្ថាប័នប្លែនិត រេទីង ហើយលទ្ធផលនឹងត្រូវប្រកាសប្រាប់ក្នុងខែ វិច្ឆិកា។

## ផលិតផលថ្មីក្នុងសង្គម

ការផ្ទេរប្រាក់តាមទូរស័ព្ទចល័តបានសម្ពោធជាផ្លូវការ ដោយធ្វើជាដៃគូជាមួយក្រុមហ៊ុនវីងកម្ពុជា ដែលជាសាខារបស់ធនាគារ អេអែនស្សិតហ្រ្គុប ដើម្បីពង្រីកច្រកផ្តល់សេវាហិរញ្ញវត្ថុ ដល់ប្រជាជនរស់នៅជនបទ ដែលមានការប្រាក់ទាប និង ចំណាយពេលខ្លី។ មានអតិថិជនចំនួន ២.000នាក់ បានចុះឈ្មោះក្នុងសេវានេះ។ វីងកម្ពុជា រំពឹងឈោងចាប់អតិថិជនចំនួន ១0.000នាក់ ក្នុងឆ្នាំ ២0១0។

កម្មវិធីកម្ចីសម្រាប់ជនរងគ្រោះដោយគ្រោះមហន្តរាយ បានគ្រោងដើម្បីចំណាយ ៣0.000ដុល្លាសម្រាប់ប្រជាជន៥00 ក្នុងចំណោមប្រជាជនកម្ពុជាដែលប៉ះពាល់ដោយខ្យល់ព្យុះ កេតសាណា ដែលបំផ្លិចបំផ្លាញនៅខែកញ្ញាកន្លងទៅ។ វីសិនហ្វាន់កម្ពុជាបានអនុម័តគោលការណ៏បញ្ចេញប្រាក់មួយភាគរយ នៃផលប័ត្រឥណទានរបស់ខ្លួនទាំងអស់ ឱ្យដល់គ្រួសារដែលប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិ និងឧប្បត្តិហេតុផ្ទាល់ខ្លួន។ ប្រាក់កម្ចីសម្រាប់ជាវទូរស័ព្ទបានផ្តល់ឱ្យប្រជាជនដែលរស់នៅតាមជនបទ ដើម្បីទិញទូរស័ព្ទដើម្បីចាប់ផ្តើមសេវាទូរស័ព្ទរបស់គេ ក្នុងភាពជាដៃគូជាមួយក្រុមហ៊ុនទូរស័ព្ទភូមិកម្ពុជា។





# ក្រុមហ៊ុនវីសិនហ្វាន់ កម្ពុជា





## អតិថិជនឆ្នើម និងកម្មវិធីអប់រំ

មានអតិថិជនឆ្នើមចំនួន ១០នាក់ ត្រូវបានជ្រើសរើសឱ្យធ្វើជាគំរូ ដែលពួកគេទទួលជោគជ័យក្នុងការប្រើប្រាស់ប្រាក់កម្ចីវីសិនហ្វាន់ ដើម្បីធ្វើឱ្យស្ថានភាពរស់នៅរបស់ពួកគេប្រសើរឡើង ហើយកូនៗរបស់គេរីករាយនឹងការអប់រំដ៏ប្រសើរ ព្រមទាំងឱកាសចូលរួមក្នុងសង្គម។ កម្មវិធីអប់រំបានបង្កើនចំនួនកូនៗរបស់អតិថិជនឱ្យទទួលអាហារូបករណ៍រហូតដល់ថ្នាក់ទី ១២ ពី ១៤នាក់ នៅក្នុងឆ្នាំ ២០០៨ ទៅ ២៤នាក់ នៅក្នុងឆ្នាំ ២០០៩ នេះ។ កម្មវិធីនេះក៏បានបង្កើតកម្មវិធីថ្នាក់បរិញ្ញាប័ត្រលើការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ ដោយសហការជាមួយនឹងសកលវិទ្យាល័យផងដែរ។

## ផ្នែកសង្គម និងកិច្ចការសាធារណៈរបស់សាជីវកម្ម

វីសិនហ្វាន់ ឈ្នះរង្វាន់កម្រិតប្រាក់ពីក្រុមពិគ្រោះយោបល់ដើម្បីជួយជនក្រីក្រ សម្រាប់តម្លាភាពក្នុងរបាយការណ៍ ផលប៉ះពាល់សង្គម ការចូលរួមពិពណ៌ពាណិជ្ជកម្ម ស្តីពីសហគ្រាសខ្នាតតូច និង មធ្យម ក៏ដូចជាលើវិស័យហិរញ្ញវត្ថុ និងធនាគារ ការឧបត្ថមកម្មវិធីវិទ្យុមួយម៉ោងចំនួន ៩ ខែ ដើម្បីផ្តល់ជាព័ត៌មានទៅម្ចាស់ សហគ្រាសខ្នាតតូច និងមធ្យម បង្កើតជាវីដេអូអំពីអតិថិជន ដែលប៉ះពាល់ដោយវិបត្តិហិរញ្ញវត្ថុពិភពលោក ដើម្បីចែកចាយជាមួយនឹងអ្នកដែលពាក់ព័ន្ធ ពីរបៀបដែលអតិថិជនទទួលផលប៉ះពាល់ ហើយមានកាសែត និងទូរទស្សន៍ ក្នុងស្រុកជាច្រើនបានផ្សព្វផ្សាយពីសកម្មភាពហិរញ្ញវត្ថុ និងសង្គមកិច្ចរបស់ក្រុមហ៊ុនវីសិនហ្វាន់។

## ការធានារ៉ាប់រងជីវិតខ្នាតតូច

មានអតិថិជនជាង ៣៣0.000 នាក់ រួមជាមួយគ្រួសារ និងកូនរបស់ពួកគេ បានទទួលការធានារ៉ាប់រងជីវិតខ្នាតតូច ដែលមានគោលការណ៍ផ្តល់ប្រយោជន៍បន្ថែមដល់អតិថិជនក្រុមហ៊ុនវីសិនហ្វាន់។

> “ យើងបានយកលុយកម្ចីទៅទិញគោ និងលក់បន្លែ ដែលចំណាយប្រហែល ៤០ ម៉ឺនរៀលក្នុងមួយថ្ងៃ។ តាំងពីបានខ្ចីប្រាក់នោះមក យើងបានបង្កើននូវប្រាក់មួយចំនួនដើម្បីទិញដីធ្លី បន្ទាប់មកក៏សាងសង់ផ្ទះមួយខ្នង។ ឥឡូវនេះយើងគេងលក់ស្រួល តែពីមុនយើងពិបាកចិត្តក្នុងការរកមុខរបរ។ ”



សាន់ យេក

# ពីជីវិតនៅលើគំនរសំរាមក្លាយជាសហគ្រិន

សាន់ យេក បានទទួលប្រាក់កម្ចីពីក្រុមហ៊ុន វីសិនហ្វាន់ កម្ពុជា តាំងពីអង្គភាពនេះជាអង្គភាពផ្តល់ឥណទាន ជាទ្រង់ទ្រាយតូចធម្មតាមួយរបស់អង្គការទស្សនៈពិភពលោកកម្ពុជាក្នុងឆ្នាំ ១៩៩៩។ បងស្រី និងប្តីរបស់គាត់ មុត ថាន កាលពីមុនបានជួលផ្ទះខ្ទមមួយនៅម្តុំកន្លែងចាក់សំរាម ស្ទឹងមានជ័យ។

បងស្រីប្រកបរបរលក់នំនៅម្តុំកន្លែងចាក់សំរាម ហើយប្តីរបស់គាត់ជាអ្នកបើកឡានចូកសំរាមឱ្យក្រុមហ៊ុនប្រមូលសំរាម។ ពួកគាត់ទាំងពីរនាក់រកប្រាក់ចំណូលបានពី ២000 រៀល ទៅ ៣000 រៀលក្នុងមួយថ្ងៃ។

អស់រយៈពេលដប់ឆ្នាំបន្តបន្ទាប់ ការខ្ចីប្រាក់ចាប់ពី ៥0.000រៀល រហូតដល់ ២ លានរៀល កម្ចីនេះបានអនុញ្ញាតឱ្យទាំងពីរនាក់ប្តីប្រពន្ធចាប់ផ្តើមប្រកបរបរអាជីវកម្មផ្សេងៗ រួមមានការចិញ្ចឹមជ្រូក ហើយមុខរបរបច្ចុប្បន្ន គឺកសិកម្មជ្រូក និងការលក់ដូរបន្លែ។ ពួកគាត់ឥឡូវនេះ រស់នៅក្នុងជីវភាពធូធារ ជាមួយនឹងកូនប្រុសឈ្មោះ ចន្ធី អាយុ ១៣ឆ្នាំ ព្រមទាំងកូនស្រីឈ្មោះ ចន្ធា អាយុ ១១ ឆ្នាំ កុមារទាំងពីរនាក់នេះរៀនថ្នាក់ទី ៦ ដូចគ្នា។

បងប្រុស មុត ថាន ជាធម្មតាទិញគោអស់ប្រហែល ៤0 ម៉ឺនរៀល គាត់ចិញ្ចឹមឱ្យចំណើវារយៈពេលមួយខែ ឬពីរខែ ហើយលក់ទៅវិញបាន ៦0ម៉ឺនរៀល ឬក៏ ៨0ម៉ឺនរៀល។ "យើងបានយកលុយកម្ចីទៅទិញគោ និងលក់បន្លែ ដែលចំណាយប្រហែល ៤0 ម៉ឺនរៀលក្នុងមួយថ្ងៃ។ តាំងពីការខ្ចីប្រាក់នោះមក យើងបានបង្កើននូវប្រាក់មួយចំនួនដើម្បីទិញដីធ្លី បន្ទាប់មកក៏សាងសង់ផ្ទះមួយខ្នង"បងស្រី សាន់ យេក ចែកចាយ។ "ឥឡូវនេះយើងគេងលក់ស្រួល តែពីមុនយើងពិបាកក្នុងការរកមុខរបរ ហើយមានការគិតច្រើន។"

បងស្រីបានបន្ថែមទៀតថា "បើគ្មានកម្ចីលុយពីក្រុមហ៊ុន វីសិនហ្វាន់ទេ ខ្ញុំប្រហែលទៅខ្ចីលុយពីអ្នកឱ្យខ្ចីជាលក្ខណៈឯកជន តែបើយើងជាអ្នកក្រ ពួកគេនឹងមិនឱ្យយើងខ្ចីលុយគេទេ សូម្បី ១0.000 ឬក៏ ២0.000 រៀល។ ឥឡូវនេះជីវិតរបស់យើងបានប្រសើរឡើង យើងមិនមែនជាអ្នកមានទេ ប៉ុន្តែយើងអាចចំអែតក្រពះរបស់យើងបាន"។

ប្រាក់ចំណូល មានការកើនឡើង ដែលបានញ៉ាំងឱ្យក្រុមគ្រួសារមានពេលរីករាយសម្រាប់ពេលទំនេរ ឬក៏ពេលឈប់សំរាកបុណ្យជាតិ និងនៅកន្លែងដែលសំខាន់សម្រាប់ការរៀនរបស់ពួកគាត់។

បងប្រុស មុត ថាន គាត់មិនសូវបានទទួលនូវការរៀនសូត្រជ្រៅជ្រះទេ រីឯប្រពន្ធរបស់គាត់រៀនចប់ថ្នាក់ទី ៦ បងប្រុសបាននិយាយថា "គ្រប់គ្នាស្វាគមន៍យើងគ្រប់កន្លែងដែលយើងទៅ ។ ពេលសម្រាកខ្ញុំយកប្រពន្ធ និងកូនៗរបស់ខ្ញុំទៅដើរលេងនៅក្រៅ ។ យើងអាចគិតពីពេលវេលាចេញទៅដើរលេង នៅពេលដែលយើងមានជីវិតល្អប្រសើរ" ។

បងប្រុស និយាយបន្ថែមទៀតថា "ខ្ញុំមានចំណេះដឹងតិចតួច ចង់ឱ្យកូនៗ របស់ខ្ញុំមានចំណេះដឹងជ្រៅជ្រះ និងខិតខំរៀនសូត្រ ដូច្នេះពួកគេអាចមានការងារធ្វើល្អ ។ សព្វថ្ងៃនេះគេត្រូវការតែអ្នកពូកែៗ ហើយសង្គមត្រូវការតែអ្នកចេះដឹងជ្រៅជ្រះ" ។ ក្នុងកាយវិការរបស់ឪពុកដែលចង់ឱ្យកូនធ្វើតាមគោលបំណងរបស់គាត់ កុមារា ចន្ទី និយាយថា "ខ្ញុំខិតខំរៀនសូត្រ ដោយសារតែខ្ញុំចង់ក្លាយទៅជាវេជ្ជបណ្ឌិតមួយរូបនៅពេលដែលខ្ញុំធំឡើង" ។





| ការចំណាយសាច់ប្រាក់តាមផ្នែកសម្រាប់ចំណាយតាមគម្រោងផ្ទាល់ | % |
|---|---|
| ផ្នែកតស៊ូមតិ | ៤,៩ |
| សង្គមស៊ីវិល | ១០,៣ |
| កម្មវិធីអប់រំ | ៥,៧ |
| កម្មវិធីសន្តិសុខស្បៀង និងទឹក | ៨,៣ |
| កម្មវិធីសុខភាព និងអាហារូបត្ថម្ភ | ១២,៤ |
| កម្មវិធីអេដស៍ | ១០,៦ |
| កម្មវិធីសន្តិភាព និងយុត្តិធម៌ | ៩,១ |
| ផ្នែកដទៃទៀត (ការតាមដាន និងវាយតម្លៃ ការគ្រប់គ្រងផ្នែកទំនុកបម្រុង ការគ្រប់គ្រងឃេនឌ័រ ការឆ្លើយតបសង្គ្រោះបន្ទាន់ ព័ន្ធកិច្ចគ្រិស្តបរិស័ទ ការអភិវឌ្ឍអ្នកដឹកនាំ ការស្ទាបស្ទង់ និងផែនការបរិស្ថាន) | ៣៨,៧ |

# របាយការណ៍ហិរញ្ញវត្ថុសង្ខេបសម្រាប់អង្គការទស្សនៈពិភពលោកកម្ពុជា

| ការចំណាយជាសាច់ប្រាក់នៅឆ្នាំសារពើពន្ធ ២០០៩ តាមប្រភេទនៃការចំណាយរបស់គម្រោង | ដុល្លារអាមេរិក | % |
|---|---|---|
| ការចំណាយតាមគម្រោងផ្ទាល់ | ១៦.១៧១.៤១០ | ៩០,៤ |
| ការចំណាយលើគម្រោងមិនផ្ទាល់ | ១.៧០៧.៩៥៨ | ៩,៦ |
| ការចំណាយលើគម្រោងសរុប | ១៧.៨៧៩.៣៦៩៨ | ១០០ |

បន្ថែមលើសាច់ប្រាក់ យើងបានទទួល និងចែកចាយដល់អ្នកខ្វះខាតនូវម្ហូបអាហារពីអង្គការកម្មវិធីស្បៀងអាហារពិភពលោក ដែលមានតម្លៃ ៦៧៩.១០៦ ដុល្លារ និងកង់មួយកុងទីន័រ ដែលជាអំណោយពីសហរដ្ឋអាមេរិកចំនួន ២៤៨ កង់។

## ការចំណាយសាច់ប្រាក់នៅឆ្នាំសារពើពន្ធ ២០០៩ តាមប្រទេសផ្តល់ជំនួយ

ប្រទេសអូស្ត្រាលី ២១,៥% • ប្រទេសកាណាដា ២០% • ប្រទេសសហរដ្ឋអាមេរិក ១៦% • ចក្រភពអង់គ្លេស ១១,៦% ប្រទេសហុងកុង ១១,៤% • ប្រទេសណូវែលសឺឡង់ ៨,៤% • ប្រទេសអាល្លឺម៉ង់ ២,៦% • ប្រទេសសិង្ហបុរី ២,២% • ប្រទេសកូរ៉េ ១,៩% ប្រទេសកម្ពុជា ១% • ប្រទេសស្វីស ១% • ប្រទេសជប៉ុន ២% • ប្រទេសហូឡង់ ០,៣% • ប្រទេសតៃវ៉ាន់ ០,៣%

១

## យើងជាគ្រិស្តបរិស័ទ

យើងបានទទួលការត្រាស់ហៅឱ្យបម្រើអ្នកដទៃក្នុងភាពបរិបូរណ៍
នៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ។

២

## យើងប្ដេជ្ញាជួយដល់ជនក្រីក្រ

យើងបានត្រូវត្រាស់ហៅឱ្យសម្រាលតម្រូវការ និងទុក្ខវេទនាភ្ជាប់ទំនាក់ទំនងរវាងអ្នកក្រ និងអ្នកមាន ។

៣

## យើងគោរពតម្លៃមនុស្ស

យើងចាត់ទុកមនុស្សទាំងអស់ថា ត្រូវបានបង្កើត និងស្រលាញ់ដោយព្រះជាម្ចាស់
ដោយម្នាក់ៗមានលក្ខណៈពិសេស ទទួលសេចក្ដីថ្លៃថ្នូរ ការគោរព និងមានតម្លៃក្នុងខ្លួន ។

៤

## យើងជាអ្នកបម្រើដែលមានការទទួលខុសត្រូវខ្ពស់

យើងស្មោះត្រង់ចំពោះគោលបំណងនៃធនធានដែលយើងបានទទួល និងគ្រប់គ្រងធនធានទាំងនោះ
ក្នុងរបៀបដែលនាំមកនូវផលប្រយោជន៍ជាអតិបរិមាដល់ជនក្រីក្រ ។

៥

## យើងជាដៃគូ

ក្នុងនាមជាសមាជិកនៃអង្គការទស្សនៈពិភពលោកអន្តរជាតិ យើងព្រមទទួលយក
កាតព្វកិច្ចដែលមានការចូលរួមគោលដៅរួម និងមានគណនេយ្យភាពទៅវិញទៅមក ។

៦

## យើងជាអ្នកឆ្លើយតប

យើងឆ្លើយតបចំពោះគ្រោះអាសន្នដែលគំរាមកំហែងដល់អាយុជីវិត ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គម
ស្មុគស្មាញដែលតម្រូវឱ្យមានការអភិវឌ្ឍយូរអង្វែង ។





អង្គការទស្សនៈពិភពលោក
គឺជាដៃគូអន្តរជាតិមួយនៃគ្រិស្តបរិស័ទ
ដែលមានបេសកកម្មដើរតាម
ព្រះអម្ចាស់ ព្រះយេស៊ូគ្រិស្តជាព្រះ
សង្គ្រោះដោយធ្វើការជាមួយជន
ក្រីក្រនិងជនរងការគាបសង្កត់ដើម្បី
បង្កើតឱ្យមានការផ្លាស់ប្រែដល់
មនុស្សជាតិ ស្វែងរកភាពយុត្តិធម៌
និងធ្វើបន្ទាល់ពីដំណឹងល្អនៃនគរព្រះ។



រចនាក្រាហ្វិក និងកាច់ទំព័រដោយ
nova: info@novacambodia.com

World Vision

អង្គការទស្សនៈពិភពលោកកម្ពុជា
ផ្ទះលេខ ២០ ផ្លូវ ៧១
សង្កាត់ទន្លេបាសាក់
ខ័ណ្ឌចំការមន
ប្រអប់សំបុត្រ ៤៧៩
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: +៨៥៥-២៣-២១៦ ០៥២
ទូរសារ: +៨៥៥-២៣-២១៦ ២២០
អ៊ីម៉ែល: cambodia@wvi.org
www.worldvision.org.kh